# ទស្សនាវដ្ដី

# សាស្ត្រាចារ្យ

ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL

ផ្សាយចេញ
រាល់ត្រីមាស
ពី

សមាគម
សាស្ត្រាចារ្យខ្មែរ

ទីស្នាក់ការ
លេខ ១៩៨ E វិថីព្រះសីហនុ ភ្នំពេញ



មករា កុម្ភៈ មិនា

ឆ្នាំ ទី ៥

លេខ
24

# មាតិការឿង


## សេចក្តីថ្វាយព្រះពរ

## ខេមរនីយកម្ម

- បេតនានិងការពិត 1
- អត្ថប្រយោជន៍នៃការសិក្សាជាភាសាខ្មែរនៅប្រទេសខ្មែរ 5
- តើអំពីភាសាខ្មែរឬភាសាបារាំង 10
- ខេមរនីយកម្មនៃការសិក្សា 17
- ខេមរនីយកម្ម 30

## បិត្តគរុកោសល្យ

- តើស្អប់ឬស្រឡាញ់មកពីមុខវិជ្ជាឬ ? 33

## វិទ្យាសាស្ត្រនិងសិល្បៈ

- ឥទ្ធិពលនៃវប្បធម៌ 38
- នៅស្ងៀមគឺថយក្រោយ 42
- ត្រូវតែគិត 43
- សប្បាយរបៀបណាទើបថ្លៃថ្នូរ 45
- សុភាសិតនិងច្បាប់កេរ្តិ៍កាល 47

## អត្ថបទនិងឯកសារ

- សេដ្ឋកិច្ចនយោបាយ 50
- វេយ្យាករណ៍អំពី "រ" 68

## ស្នូរជួងសាលា 75

## ជីវភាពមិត្តយើង 78

## ហិបប្រាក់សមាគម 81

## យើងឆ្លើយឆ្លងគ្នា 83



## សេចក្ដីថ្វាយព្រះពរ

នៅក្នុងឱកាសព្រះរាជពិធីចំរើនព្រះជន្មវស្សា នឹងក្នុងឱកាសឆ្នាំថ្មីនេះ ទូលព្រះបង្គំទាំងឡាយជាសមាជិកគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

សូមព្រះរាជវរោកាស ប្រសិទ្ធិថ្វាយព្រះអង្គនូវពរសព្ទសាធុការ ដ៏វិសេសវិសាល ដើម្បីព្រះមហាជោគជ័យ សិរីមង្គលវិបុលសុខគ្រប់ប្រការ ដើម្បីទ្រង់គង់ជាម្លប់ដ៏ត្រជាក់ត្រជុំនៃកូនចៅព្រះអង្គជាដរាបតរៀងទៅ ។

ទូលព្រះបង្គំទាំងឡាយ សូមប្ដេជ្ញាដង្ហែតាមព្រះអង្គនៅលើមាគ៌ាដ៏រុងរឿង នៃព្រះរាជនយោបាយឯករាជ្យ បង្រួបបង្រួមជាតិ និងវឌ្ឍនភាពរបស់សម្ដេចឪរហូតដល់ជោគជ័យជាអវសាន ។

សូមក្រាបបង្គំទូលថ្វាយ នៅថ្ងៃ ៨ មេសា ១៩៦៧

សេចក្ដីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស.

ជ. គណៈកម្មាធិការនាយក

ប្រធានសមាគម មាស ឌឹម

★

ភ្នំពេញ នៅថ្ងៃទី ១០ ខែឧសភា ១៩៦៧

អ្នកអង្គម្ចាស់ អគ្គនាយកក្រសួងនានានៃព្រះបរមរាជវាំង
ជំរាបមកសហជីវិន មាស ឌឹម ប្រធានសមាគមសាស្ត្រាចារ្យ
លេខ ១៩៨ វិថីព្រះសីហនុ ភ្នំពេញ ជានជ្រាប ។

សម្ដេចព្រះមហាក្សត្រីយានី ជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានទទួលនូវបុគហ្វាយលេខ ២០ គ.ន ១០ ចុះថ្ងៃ ៨ មេសា ១៩៦៧ ដែលសហជីវិន និងសមាជិកគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ បានប្រសិទ្ធិសព្ទសាធុការពរចំពោះព្រះអង្គ ក្នុងឱកាសព្រះរាជពិធីចំរើនព្រះជន្មវស្សា និងឱកាសចូលឆ្នាំថ្មីនេះ ។

សម្ដេចជាអម្ចាស់ ទ្រង់ត្រាសបង្គាប់ឲ្យខ្ញុំថ្លែង នូវព្រះរាជអំណរគុណ ដ៏ជ្រាលជ្រៅព្រមទាំងព្រះរាជទានពរតបវិញ សូមសហជីវិន និងសមាជិកគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ បានជួបប្រទះនឹងសេចក្ដីសុខ ចំរើន ជានិរន្តរតរៀងទៅកុំបីឃ្លាតឡើយ ។

សូមសហជីវិនទទួល នូវសេចក្ដីរាប់អានដ៏ស្មោះចំពោះអំពីខ្ញុំ ។

នរោត្តម កន្តុល



# សេចក្តីថ្វាយព្រះពរ

ក្នុងឱកាសឆ្នាំថ្មីនេះ ទូលព្រះបង្គំទាំងឡាយជាសមាជិកគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

សូមព្រះរាជវរោកាស ប្រសិទ្ធិនូវពរសព្ទសាធុការ ដ៏វិសេសវិសាលបំផុតថ្វាយអង្គសម្តេច៖ សូមព្រះអង្គទ្រង់ស្ថិតនៅតែក្នុងព្រះសុខុមាលភាព នឹងព្រះសុខភាពដ៏បរិបូណ៌ ដើម្បីជាទីពំនាក់នៃកូនចៅព្រះអង្គទាំងអស់ ។

ទូលបង្គំទាំងឡាយ សូមបួងសួងដល់ទេវតាឆ្នាំថ្មី សូមឲ្យផ្សព្វផ្សាយនូវព្រះតេជានុភាពថ្វាយព្រះអង្គ ដើម្បីទ្រង់គង់នៅជាព្រះអគ្គមគ្គុទ្ទេសក៍ ដ៏ឆ្នើមបំផុតនៃកម្ពុជរដ្ឋ ក្នុងដំណើរឆ្ពោះទៅរកសេចក្ដីសុខ ចំរើន បង្រួបបង្រួមជាតិ និងក្នុងការពុះពារឧបសគ្គផ្សេងៗ ដែលពួកមារសត្រូវចក្រពត្រអាមេរិកាំង នឹងបរិវារបង្កបង្កើតឡើង ។

ទូលព្រះបង្គំទាំងឡាយ សូមប្ដេជ្ញាថ្វាយកាយនិងជីវិតដង្ហែតាមព្រះអង្គនៅលើមាគ៌ាដ៏រុងរឿងខាងលើនេះ រហូតដល់ជោគជ័យជាអវសាន ។

សូមក្រាបបង្គំទូលថ្វាយ ភ្នំពេញ នៅថ្ងៃ ៨ មេសា ១៩៦៧

សេចក្ដីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស.

ជ. គណៈកម្មាធិការនាយក

ប្រធានសមាគម

★

ភ្នំពេញ នៅថ្ងៃទី ២០ ខែមេសា គ.ស.១៩៦៧

នាយកខុទ្ទកាល័យសម្ដេចសហជីវិនព្រះប្រមុខរដ្ឋ

ជំរាបមក សហជីវិន មាស ឌឹម ប្រធានសមាគមសាស្ត្រាចារ្យខ្មែរ ក្រុងភ្នំពេញ

តបតាមលិខិតលេខ ១៨ គ.ន ១០ ចុះថ្ងៃទី ៨ ខែមេសា គ.ស. ១៩៦៧

ខ្ញុំមានសោមនស្សយ៉ាងអនេក ដែលបានទទួលព្រះបរមរាជឧង្ការ នូវព្រះបន្ទូលសូរសីហនាទសម្ដេចព្រះប្រមុខរដ្ឋ ឲ្យខ្ញុំតបមកសហជីវិនក្នុងព្រះបរមនាមព្រះអង្គ នូវព្រះអំណរគុណដ៏លើសលុប ចំពោះព្រះពរស័ព្ទសាធុការដែលសហជីវិនជាសមាជិក - សមាជិកាសមាគម បានថ្វាយដល់ព្រះអង្គក្នុងឱកាសចូលឆ្នាំ មមែនព្វស័ក ព.ស ២៥១០ នេះ ។

នៅទីបំផុត ព្រះអង្គទ្រង់ប្រទានពរស័ព្ទសាធុការជោគជ័យដ៏ប្រសើរ ដល់សហជីវិនីនិងសហជីវិនវិញ សូមឲ្យបានប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺ: អាយុ: វណ្ណ: សុខ: ពល: និងបដិភាណ: អស់កាលជានិរន្ដរ៍ ។

សូមទទួលនូវសេចក្ដីរាប់អានជាភាតរភាពអំពីខ្ញុំ ។

អ៊ឹង ហុងសាធ



គណៈកម្មាធិការនាយក នៃ ស.ស.ខ

សូមប្រសិទ្ធិ ក្នុងឱកាសឆ្នាំថ្មីនេះ នូវពរសព្ទសាធុការ ដ៏ប្រសើរ
សព្វបែបយ៉ាង ជូនមិត្តព្រមទាំងគ្រួសារទាំងអស់ សូមឱយប្រកបតែ
នឹងសេចក្ដីសុខ ចំរើនជាដរាបរៀងទៅ ដើម្បីនឹងធ្វើវិភាគទាន ឱយ
បានជាអតិបរមា ក្នុងកិច្ចកសាងជាតិយើង !

## ខេមរនីយកម្ម

ការចង់ធ្វើឲ្យកូនខ្មែរពូកែបារាំង គឺគ្រាន់តែជាការចង់តែប៉ុណ្ណោះ ។ សៀវភៅបង្រៀនបែបណា វិធីបង្រៀនបែបណា គរុកោសល្យសក្តិសិទ្ធិបែបណា ក៏ពុំអាចនាំទៅដល់ទីដៅបែបនេះឡើយ ។ មែនពិត គេអាចធ្វើឲ្យអ្នកឆើត Elites មួយចំនួនពូកែបារាំងបានខ្លះដែរ តែសូមកុំរំពឹងទុកឲ្យសោះថា អាទិទេពណាមួយអាចធ្វើឲ្យកូនខ្មែរទូទៅ ខ្មែរទាំងអស់ចេះបារាំង ពូកែបារាំង ដូចជាគេពុំត្រូវរំពឹងថា គេអាចនឹងធ្វើឲ្យកូនបារាំងទូទៅចេះខ្មែរ ពូកែខ្មែរយ៉ាងនោះដែរ ។ គិតធ្វើឲ្យជាតិមួយ ដែលមានភាសាពិសេស អក្សរពិសេស វប្បធម៌ អរិយធម៌ពិសេសរបស់ខ្លួន រាប់សិប រាប់រយសតវត្សទៅហើយ ផ្លាស់ប្តូររបៀបគិត របៀបយល់ ដើម្បីទៅគិត ទៅយល់តាមបែបបារាំង បែបឃ្លាប្រយោគបារាំង បែបវប្បធម៌ អរិយធម៌បារាំង ឬបែបបរទេសណាមួយទៀត គឺគ្រាន់តែនាំឲ្យឈឺក្បាលខ្លួនឯងអតប្រយោជន៍ផង នាំឲ្យឈឺក្បាលរបស់កូនក្មេងផង ។ ការពិតនេះ ពុំមែនមានតែចំពោះស្រុកខ្មែរ

កូនខ្មែរតែប៉ុននោះទេ ។ ការតំរូវឲ្យជាតិណាក៏ដោយ រៀនភាសាបរទេសមួយទៀតដទៃពីភាសាជាតិរបស់ខ្លួន សុទ្ធតែជួបនឹងការទាល់ច្រកបែបនេះទាំងអស់ ។ សូម្បីតែពួកអាណានិគមនិយមបារាំងបានខំព្យាយាមកែប្រែការពិតនេះ តាមគ្រប់មធ្យោបាយ ចំនួនជិតមួយសតវត្ស ដូចជាតំរូវឲ្យកូនខ្មែររៀនភាសានិងអក្សរបារាំង តាំងតែពីថ្នាក់កុមារដ្ឋានជាដើម ក៏គេនៅតែទៅពុំដល់គោលដៅរបស់គេដែរ ។ នេះជាការពិតមួយ ដែលពុំខ្ចីផ្លាស់ប្តូរប្រែប្រួលទៅតាមចេតនារបស់អ្នកណាទាល់តែសោះ ។

ដោយយល់យ៉ាងនេះហើយ បានជាប្រទេសនានាដែលគ្មានជំលោះខាងភាសាទេនោះ រមែងតែងតែលើកយកភាសាជាតិរបស់ខ្លួន មកធ្វើជាភាសាយានក្នុងការសិក្សា ។ មិនតែប៉ុននោះ គេបានទាំងជួយបង្កើតអក្សរឲ្យជនជាតិភាគតិច Monorités របស់គេខ្លះ ដែលមានភាសាហើយ តែពុំទាន់មានអក្សរនៅឡើយថែមទៀតផង ។

★

ចំពោះប្រទេសយើង សព្វថ្ងៃនេះ មតិដែលយល់ថា ត្រូវតែយកភាសាខ្មែរមកធ្វើជាភាសាយានក្នុងការរៀនសូត្រ កាន់តែរីកចំរើន កើនចំនួនឡើងៗ ជាពិសេសក្នុងមជ្ឈដ្ឋានគ្រូបង្រៀននិងសាស្ត្រាចារ្យយើង ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏ ‘‘ជំងឺពុំទុកចិត្តលើភាសាអក្សរជាតិ,, នៅពុំទាន់ជាសះស្បើយមែនទែននៅឡើយ ។ អ្នកកើតជំងឺបែបនេះ ច្រើនតែពោលត្អូញត្អែថា ភាសាខ្មែរខ្វះពាក្យច្រើនណាស់ ដូចជាពាក្យតិចនិច ពាក្យវិជ្ជា ពាក្យអ្នកប្រាជ្ញ. . . តែជាពិសេសនៅខ្វះសៀវភៅ ដើម្បីធ្វើឲ្យការសិក្សាប្រព្រឹត្តទៅតាមភាសា

ជាតិបាន ។ ចំពោះយើងវិញ យើងយល់ថា ភាសាអក្សរខ្មែរ ដែលដូនតាយើងធ្លាប់បានប្រើ ដើម្បីតែងនិពន្ធរឿងពមកេរ្តិ៍ ដើម្បីរៀនទាំងបង្រៀនវិជ្ជាផ្សេងៗ ពិសេសវិជ្ជាសង់ប្រាសាទថ្ម ដ៏ល្អគ្មានពីរ ដើម្បីជីកព្រែក ជីកបារាយ ធ្វើថ្នល់ ធ្វើស្ពាន បើពោលឲ្យខ្លី ដើម្បីកសាងជាតិនោះ ពិតជានៅតែមានសមត្ថភាពដដែល - មានសមត្ថភាព ដូចជាភាសាចិន ជប៉ុន បារាំង អង់គ្លេស . . . ដែរ ។ រីឯរឿងខ្វះសៀវភៅសិក្សាជាភាសាជាតិវិញ ក្នុងពេលថ្មីៗនេះ សមាគមយើងបានទាក់ទងនឹងមិត្តសាស្ត្រាចារ្យមួយចំនួននៅភ្នំពេញ និងនៅតាមខេត្តក្រៅខ្លះឲ្យប្រមូលផ្តុំគ្នាចងក្រងមេរៀនជាខ្មែរ តំរូវទៅតាមកម្មវិធីសិក្សាថ្មី នៃថ្នាក់ទី ៦ ទំនើប ។ បើប្រសិនជាការងារដ៏ប្រសើរនេះសំរេចបានក្នុងឆ្នាំនេះ ឆ្នាំក្រោយ យើងនឹងសូមឲ្យមិត្តយើងបន្តការនេះ ដល់ថ្នាក់ទី ៥ ទី ៤ ទី ៣ . . . តទៅទៀត ។ ប៉ុន្តែយើងជឿថា បើគ្មានឧបសគ្គអ្វីមកពាំងទេ ក្រសួងអប់រំជាតិដែលចង់ឲ្យការសិក្សាប្រព្រឹត្តទៅតាមរយៈភាសាជាតិដែរ អាចនឹងធ្វើឲ្យការចងក្រងសៀវភៅជាភាសាខ្មែរ មានភាពសក្តិសិទ្ធិ៍ជាងយើងឆ្ងាយណាស់ ។

★

សូមបញ្ជាក់ជាបញ្ចប់ថា យើងពុំប្រឆាំងនឹងការរៀនភាសាបារាំងឡើយ ។ យើងគ្រាន់តែយល់ថា ត្រូវទុកភាសាបារាំងជាភាសារស់ Langue vivante ដូចភាសាអង់គ្លេសទៅវិញតែប៉ុណ្ណោះ ហើយបើមានពេលច្រើន យើងសូមស្នើឲ្យបញ្ចូលភាសារស់នៃជាតិផ្សេងៗមកក្នុងកម្មវិធីសិក្សាយើងថែមទៀត ដើម្បីឲ្យសំបូរ “បង្អួច” សំរាប់អើតមើលទេសភាពល្អៗក្រៅផ្ទះ នឹងដើម្បីឲ្យខ្យល់ល្អចេញចូលផ្តល់សុខភាពដល់ផ្ទះខ្មែរយើង ។

ជយោ ភាសា អក្សរខ្មែរ !

— វប្បធម៌ អរិយធម៌ខ្មែរ !

### មតិមិត្តយើងចំពោះ

# បញ្ហាខេមរនីយកម្ម

## អត្ថប្រយោជន៍នៃការសិក្សា
## ជាភាសាខ្មែរ នៅប្រទេសខ្មែរ

ជាទូទៅ មនុស្សគួរឲ្យមានសម្បត្តិ ៣ ប្រការ គឺ រូបសម្បត្តិ វិជ្ជាសម្បត្តិ និង ចរិយាសម្បត្តិ ។ ក្រសួងអប់រំជាតិជាអ្នកទទួលភារៈមួយផ្នែកធំ ក្នុងការផ្តល់សម្បត្តិទាំង ៣ យ៉ាងនេះដល់ពលរដ្ឋ ។ ពីព្រោះតែមានភារៈដូចនេះហើយ បានជាគេផ្លាស់ឈ្មោះក្រសួងសិក្សាធិការជាតិ មកជាក្រសួងអប់រំជាតិវិញ ។ ក្រសួងសិក្សាធិការមានការងារគ្រាន់តែផ្តល់នូវចំណេះវិជ្ជា បានសេចក្តីថា វិជ្ជាសម្បត្តិប៉ុណ្ណោះ ។ រីឯក្រសួងអប់រំជាតិវិញ មានមុខងារអប់រំរូបកាយឲ្យមានទ្រង់ទ្រាយល្អល្អះ មានសុខភាពបរិបូណ៌ ហើយឲ្យមានវិជ្ជា និង ចរិយាសម្បត្តិប្រសើរថ្លៃថ្លាទៀតផង បានសេចក្តីថា ធ្វើឲ្យមានសម្បត្តិទាំង ៣ ប្រការ ខាងលើនោះ ។

ដើម្បីឲ្យការផ្តល់សម្បត្តិទាំង ៣ ប្រការនេះ បានសំរេចបរិបូណ៌ ក្រសួងអប់រំជាតិគួរគប្បីធ្វើឲ្យការសិក្សាប្រព្រឹត្តទៅជាភាសាជាតិ ។ កាលណាក្រសួងអប់រំជាតិ យកភាសាជាតិមកធ្វើជាភាសាយានក្នុងការសិក្សា បានសេចក្តីថាមានលក្ខណៈជាតិ ក្រសួងអប់រំនោះនឹងផ្តល់ផលប្រយោជន៍ច្រើនបែប ច្រើនយ៉ាងណាស់ដល់ប្រទេសជាតិមាតុភូមិ ។

ការសិក្សារបស់ខ្មែរយើងសព្វថ្ងៃប្រព្រឹត្តទៅតាមភាសាបារាំង ។ ដើម្បីរៀនគណិតវិជ្ជា ភូមិវិជ្ជា ប្រវត្តិវិជ្ជា ឬ រូបវិជ្ជា ។ល។ សិស្សខ្មែរត្រូវចេះភាសាបារាំងជាដាច់ខាត ។ តាមការសង្កេតទូទៅ ហើយប្រហែលជាការពិតទៅហើយ នរណាក៏ពោលដែរថា សិស្សសព្វថ្ងៃខ្សោយភាសាបារាំងណាស់ ធ្វើឃ្លាមិនត្រឹមត្រូវ និយាយពន្យល់ជាបារាំងស្ដាប់មិនបាន ជាកិច្ចនាំឲ្យ គ្រូ ឬ សាស្ត្រាចារ្យជាខ្មែរ ត្រូវបង្ខំចិត្តពន្យល់មេរៀនសរសេរជាបារាំង តាមភាសាខ្មែរ ។ ប្រសិនបើសិស្សខ្សោយបារាំងដែលជាភាសាយានយ៉ាងដូចនេះ តើធ្វើម្ដេចឲ្យសិស្សនោះអាចយល់មេរៀនជាបារាំងរបស់ខ្លួនបាន ? ហើយប្រសិនបើយល់ ក៏យល់ដោយសារតែលោកគ្រូខ្មែរ បកប្រែជាខ្មែរប៉ុននោះ តើធ្វើម្ដេចឲ្យគាត់អាចសរសេរសំដែងមកវិញបានយ៉ាងស្រួលនឹងយ៉ាងត្រឹមត្រូវបាន ក្នុងពេលប្រឡងឆមាស ឬ ក្នុងពេលប្រឡងធម្មតា ពីព្រោះក្នុងការប្រឡងនោះ ក្រសួងអប់រំជាតិ បានតម្រូវឲ្យសរសេរជាភាសាបារាំងទៅហើយ ? យើងឃើញមានតែមធ្យោបាយទន្ទេញចាំមាត់ប៉ុននោះឯង . . . ។

ការរៀនដោយទន្ទេញចាំមាត់ នរណាក៏ដឹងដែរថា មិនធ្វើឲ្យការសិក្សាមានការលូតលាស់រីកចំរើន មិនសម្រួចបញ្ញាសិស្សឲ្យមុតថ្លា ដើម្បីមានចំនាច ( សមត្ថភាព ) នឹងស្រាវជ្រាវពង្រីកវិជ្ជាផ្សេងផ្សេង សម្រាប់ឆ្លើយតបនឹងសេចក្ដីត្រូវការរបស់ប្រទេសជាតិបានឡើយ ។ ប្រសិនបើយើងបង្រៀនជាខ្មែរវិញ យើងអាចហ៊ានអះអាងបានថា សិស្សមុខជាឆាប់យល់ ឆាប់ចេះ ឆាប់ចាំ សប្បាយចិត្តនឹងរៀនជាងច្រើនណាស់ ។

ធ្វើម្ដេចឲ្យរៀនជាខ្មែរបាន បើគ្មានសៀវភៅ ?

យើងសូមឆ្លើយថា បើគ្មានសៀវភៅទេ យើងធ្វើឲ្យមានទៅ ។ ការគ្មានសៀវភៅមិនមែនជាបញ្ហាដោះស្រាយមិនរួចឯណា ។ ក្រសួងអប់រំជាតិ អាចបង្កើតគណៈកម្មការផ្សេងផ្សេង សម្រាប់ប្រែ ឬ សរសេរសៀវភៅជាខ្មែរគ្រប់មុខវិជ្ជាទាំងអស់បាន ។ ពិតមែនហើយ មុនដំបូងសៀវភៅនោះមិនអាចមានលក្ខណៈល្អគ្រប់សព្វទេ ប៉ុន្តែ ពីរ បី ឆ្នាំបន្ទាប់មក វានឹងទៅជាល្អប្រសើរពុំខាន ។

កាលណាមានសៀវភៅសិក្សាជាខ្មែរ ធ្វើនៅស្រុកខ្មែរ ខ្មែរមិនគ្រាន់តែឈប់ចំណាយរូបិយប័ណ្ណប្រាក់កាស ទៅទិញសៀវភៅនៅស្រុកបារាំងទាំងលាននោះទេ ប៉ុន្តែជាការធ្វើឲ្យអ្នកនិពន្ធសៀវភៅវិសេស វិសេសជាតិខ្មែរ មានសំណាងនឹងលក់សៀវភៅរបស់ខ្លួនដាច់ច្រើន បំណេញបានប្រាក់កាសលៀងជីវិតថែមទៀត ដែលជាកិច្ចធ្វើឲ្យមានកម្លាំងចំធ្វើការស្រាវជ្រាវឲ្យបានកាន់តែចំរើនឡើងពុំឈប់ឈរ ។

ម្យ៉ាងទៀត ការធ្វើសៀវភៅសិក្សាជាខ្មែរ ខ្មែរអាចបោះពុម្ពប៉ុន្មានក្បាលក៏បានដែរ តម្រូវតាមសេចក្តីត្រូវការរបស់អ្នករៀន ។ ដូចនេះយើងសង្ឃឹមថា សិស្សនឹងនិស្សិតខ្មែរទូទៅ មុខជានឹងមានសៀវភៅរៀនគ្រប់គ្រាន់ពុំខាន មិនដូចសព្វថ្ងៃ ចាំតែកត់ពីការបង្រៀនរបស់គ្រូប៉ុននោះឡើយ ។

យើងមិនគ្រាន់តែបានផលប៉ុននេះទេ កាលណាយើងប្រើភាសាខ្មែរក្នុងការសិក្សារបស់យើង សិស្ស នឹង និស្សិតខ្មែរយើងនឹងចេះដឹងវិជ្ជាផ្សេងផ្សេងជាខ្មែរ ជាកិច្ចដល់ថ្ងៃក្រោយទៅ នាំឲ្យអ្នករៀនទាំងនោះអាចសរសេរសៀវភៅពីវិជ្ជា ពីការចេះដឹងផ្សេងផ្សេងបានយ៉ាងស្រួល ពីព្រោះដោយបានរៀនជាខ្មែរ យល់អស់អាថ៌ អស់នោម ហើយចេះពាក្យខ្មែរគ្រប់គ្រាន់មិនស្ទាក់ស្ទើរ ។ ការនេះនាំឲ្យប្រទេសយើងសំបូណ៌សៀវភៅ ដូចជាប្រទេសដទៃពុំខាន ហើយមិនគ្រាន់តែប៉ុននោះ យើងអាចតុបតែងសរសេរសៀវភៅសិក្សា ឲ្យស្របទៅតាមកម្មវិធីសិក្សាខ្មែរយើង ដែលធ្វើឡើងដោយយោលទៅតាមលក្ខណៈសង្គម លក្ខណៈនយោបាយ លក្ខណៈសេដ្ឋកិច្ចរបស់ជាតិយើងថែមទៀតផង ។ ការធ្វើយ៉ាងនេះនាំឲ្យយើងមានឯករាជ្យបរិបូណ៌ក្នុងវប្បធម៌ជាតិ ។ ប្រសិនបើយើងនៅពឹងលើសៀវភៅបរទេសទាំងស្រុង យើងមិនអាចអនុវត្តកម្មវិធីសិក្សាមួយដែលយោលទៅតាមលក្ខណៈជាតិបានទេ ពីព្រោះជនបរទេស គេមិនបានគិតសរសេរសៀវភៅ តម្រូវតាមសេចក្តីត្រូវការរបស់យើងឡើយ ។

សេចក្ដីដូចបានអធិប្បាយរួចមកហើយ នាំឲ្យយើងឃើញថាការសិក្សាជាភាសាខ្មែរ នាំឲ្យសិស្ស និស្សិតខ្មែរស្រណុករៀន ចូលចិត្តរៀន ពីព្រោះឆាប់យល់ ឆាប់ចេះ ឆាប់ចាំ នាំឲ្យប្រទេសខ្មែរសំបូណ៌សៀវភៅវិជ្ជាផ្សេងផ្សេង ព្រមទាំងសៀវភៅមើលធម្មតា ដែលល្អប្រសើរ នាំឲ្យ ជាទីបំផុត ក្រសួងអប់រំជាតិអាចផ្ដល់ដល់សិស្ស នឹង និស្សិត នូវវិជ្ជាសម្បត្តិ បានយ៉ាងស្រួល អស់ពេលតិច ហើយបរិបូណ៌ទៀតផង ។

កាលណាសិស្ស នឹង និស្សិតអាចរៀនឆាប់ចេះ ឆាប់យល់ ឆាប់ចាំ គេនឹងមានពេលទំនេរច្រើន គេអាចសម្រាកបានគ្រប់គ្រាន់ដើម្បីរក្សាសុខភាពឲ្យបានល្អ ដើម្បីជៀសវាងជម្ងឺដែលកើតឡើងពីការធ្វើហួសកម្លាំង គេអាចលេងកីឡា ទៅហាត់ប្រាណឲ្យមានរូបរាងល្អល្អះ ទៅធ្វើការហត្ថកម្មបានយ៉ាងគាប់ចិត្ត លែងព្រួយបារម្ភថាគ្មានពេលរៀន ថាធ្វើកិច្ចការសាលាមិនទាន់ ។ ត្រង់ចំណុចនេះ យើងឃើញថាក្រសួងអប់រំជាតិអាចផ្ដល់ដល់សិស្ស នឹងនិស្សិតនូវសម្បត្តិម្យ៉ាងទៀត គឺរូបសម្បត្តិដែលជាទ្រព្យសំខាន់មួយរបស់ពលរដ្ឋឯករាជ ដើម្បីកសាងសង្គមមនុស្សស្អាតស្អំ ។

ការសិក្សាជាភាសាជាតិ នាំឲ្យជនជាតិខ្មែររឹតតែមានសេចក្ដីស្នេហាជាតិ និយមជាតិដោយមិនងឹតងងុលកាន់តែខ្លាំងឡើង ពីព្រោះដោយយល់ឃើញថា ភាសាខ្លួនមានតម្លៃ ជាតិខ្មែរក៏មានតម្លៃ ភាសាខ្លួនជាខ្មែរក៏មានកិត្តិយស ហើយរីករាយចិត្តនឹងរស់នៅជាខ្មែរ រួចហើយមានសេចក្ដីស្វិតស្វាញតស៊ូកសាងប្រទេសជាតិដ៏មានតម្លៃរបស់ខ្លួនយ៉ាងផ្ដួរផ្ដាច់ ស្លាប់រស់មិនគិត ។ គឺវប្បធម៌ជាតិនេះហើយដែលបណ្ដុះសេចក្ដីស្នេហាជាតិឲ្យដុះឡើងយ៉ាងរឹងប៉ឹងមិនរង្គោះរង្គើក្នុងសន្ដានចិត្តពលរដ្ឋ ។

ការសិក្សារបស់ជនជាតិបារាំងបានធ្វើឡើងដោយភាសាជាតិរបស់គេ ដូចនោះហើយជនជាតិគេស្រឡាញ់ភាសាគេណាស់ ហើយសេចក្ដីស្នេហានេះនាំឲ្យគេកាន់តែសំអិតសំអាងភាសាគេឲ្យរីកដុះដាល សំរាប់សេចក្ដីចំរើនរុងរឿងរបស់ប្រទេសគេ ។

ប្រទេសខ្មែរយើងក៏នឹងទៅដូចនោះដែរ  នៅពេលដែលការសិក្សាយើងធ្វើឡើងតាមភាសាជាតិយើង ។

ដូចនេះ  កាលណាយើងរៀនជាភាសាជាតិ  ក្រសួងអប់រំជាតិអាចផ្តល់ដល់ពលរដ្ឋយើងនូវសម្បត្តិម្យ៉ាងទៀត ដែលជាសម្បត្តិសំខាន់បំផុត  គឺចរិយាសម្បត្តិនោះឯង  ពីព្រោះសេចក្តីស្នេហាជាតិជាធាតុធំបំផុតមួយនៃចរិយាសម្បត្តិ ។

សេចក្តីទាំងឡាយដែលយើងបានពប់រៀបតាំងពីដើមមក  នាំឲ្យយើងឃើញថា ប្រសិនបើចង់ឲ្យក្រសួងអប់រំជាតិផ្តល់ដល់ពលរដ្ឋនូវសម្បត្តិទាំង ៣ យ៉ាងខាងលើ ពោលគឺវិជ្ជាសម្បត្តិ  រូបសម្បត្តិ  និង  ចរិយោសម្បត្តិឲ្យបានបរិបូណ៌ជាទីគាប់ចិត្ត  ហើយទាន់សេចក្តីត្រូវការ  យើងគួរគប្បីធ្វើឲ្យការសិក្សារបស់យើង  ប្រព្រឹត្តទៅតាមភាសាជាតិរបស់យើង ដូចជាប្រទេសចំនួនច្រើនដែលទើបនឹងបានឯករាជ្យដូចយើង ។

យើងចង់កសាងប្រទេសជាតិឲ្យសំបូណ៌  សប្បាយ ស្អាតស្អំ ។ ដើម្បីសម្រេចគោលបំណងនេះ  យើងត្រូវមានពលរដ្ឋដែលមានសេចក្តីស្នេហាជាតិយ៉ាងជ្រាលជ្រៅ ។  ចុះធ្វើម្តេចឲ្យពលរដ្ឋយើងមានសេចក្តីស្នេហាបែបនោះ  ប្រសិនបើគ្នាមិនស្គាល់តម្លៃជាតិខ្លួនឯងផង?  ចុះធ្វើដូចម្តេចឲ្យស្គាល់តម្លៃជាតិខ្លួនឯង  ប្រសិនបើគ្នាមិនសាល់វប្បធម៌ជាតិខ្លួនឯងផង ?  ចុះធ្វើដូចម្តេចឲ្យស្គាល់វប្បធម៌ជាតិខ្លួនឯង  ប្រសិនបើមិនរៀនជាភាសាខ្មែរផង ?

ប្រសិនបើយើងមិនដោះស្រាយបញ្ហានេះទេ  សេចក្តីស្នេហាជាតិរបស់ខ្មែរយើងមិនមានឫសកែវរឹងប៉ឹង  ដុះជាប់នឹងសន្តានចិត្តខ្មែរយើងឡើយ ។

រួមសេចក្តីមក យើងឃើញថា  ក្រសួងអប់រំជាតិជាអ្នកផ្តល់សម្បត្តិ ៣ យ៉ាង ដល់ពលរដ្ឋខ្មែរ  គឺ  វិជ្ជាសម្បត្តិ  រូបសម្បត្តិ  និង ចរិយាសម្បត្តិ  ហើយយើងឃើញទៀតថា  ដើម្បីសម្រេចគោលបំណងដ៏ប្រសើរនេះ  ក្រសួងអប់រំជាតិគួរគប្បីមានលក្ខណៈជាតិឲ្យច្បាស់លាស់ ពោលគឺយកភាសាជាតិមកធ្វើជាភាសាយានក្នុងការសិក្សា  រៀនយកវិជ្ជាផ្សេងផ្សេង ដែលជាការចាំបាច់សម្រាប់សេចក្តីចំរើនរុងរឿង  និង  ឯករាជ្យនៃប្រទេសជាតិយើង ។

# តើអំពី
# ភាសាខ្មែរ ឬ ភាសាបារាំង ?

អាំ ជួង និង ម៉ម បត្ថជា

អ្វីៗ ទាំងអស់នៅនាលោកទាំងមូលនេះ តែងតែប្រែប្រួល ចំរើនទៅមុខជានិច្ច គ្មានឈប់ មិនខ្វីវិលត្រឡប់ក្រោយជាដាច់ខាត ។ សភាពនេះ គឺជាធម្មតានៃមនុស្ស នៃធម្មជាតិ នៃវិទ្យាសាស្ត្រ . . . យ៉ាងជាក់ប្រាកដណាស់ ។ នៅកម្ពុជាយើង ការសិក្សានូវមុខវិជ្ជាខ្លះៗ ជាភាសាខ្មែរក៏បានចំរើនមួយកំរិតដែរ . . . ។

ប៉ុន្តែ... ខ្មែរភាគខ្លះនាំគ្នាចាប់អារម្មណ៍យ៉ាងខ្លាំង លើបញ្ហាសិក្សាភាសាបារាំង ។ ហើយផ្ទុយទៅវិញ ខ្មែរភាគនោះពុំខ្វីរវល់ទឹកនាគិតដល់បញ្ហាសិក្សាភាសាខ្មែរសោះ ។ មានទស្សនៈបែបនេះ នាំឲ្យគេទាំងនោះសំឡឹងទៅឃើញថា កូនខ្មែរឥឡូវចុះខ្សោយខាងភាសាបារាំង ជាងខ្មែរជាន់មុនជាខ្លាំង ។ ការសំឡឹងឃើញបែបនេះ នាំឲ្យគេលើកបញ្ហាការកែប្រែកម្មវិធីសិក្សា និងការផ្លាស់សៀវភៅ (ពិសេសសៀវភៅសំរាប់សិក្សាភាសាបារាំង) សំរាប់បង្រៀនមករិះគន់ ។ ការរិះគន់បែបនេះនាំឲ្យកើតនូវសង្គ្រាមប៉ាកាដែលជាទំនាស់រវាងអ្នកចាស់ និងអ្នកថ្មី ហើយជាពិសេសរវាងជាតិខ្មែរ ដែលជាសាស្ត្រាចារ្យបង្រៀនភាសាបារាំងនៅកម្ពុជា ។

លោកខ្លះនិយមឲ្យតម្លៃលើវិធី Mauger លោកខ្លះទៀតនិយមឲ្យការសិក្សាភាសាបារាំង វិលត្រឡប់ថយក្រោយទៅរកវិធីចាស់វិញ ( វិធីដែលគេប្រើកាលជំនាន់អាណាព្យាបាល ) លោកខ្លះទៀតថាត្រូវផ្លាស់សៀវភៅ Mauger ចេញ ហើយរកសៀវភៅណាថ្មីទៀតមកប្រើជំនួសវិញ លោកខ្លះទៀតថាមកពីលុបវិញ្ញាសា សរសេរតាមសូត្របារាំង ពីការប្រឡងឌីប្ល៉ូមបានជាក្មេងខ្សោយបារាំង. . . ច្រើនណាស់ ! រាប់ពុំអស់ទេ !

បញ្ហាចំនាស់នេះមានសភាព ហាក់ដូចជាគេនាំគ្នាមុជកវែកម្ជុលមួយតូច ដែលជ្រុះទៅក្នុងមហាសាគរដ៏ធំធេងល្វេងល្វើយអញ្ចឹង ៗ គ្មានបានផលអ្វីល្អសោះ! គឺបានតែនាំគ្នាបង្អាក់ និង បំភ្លេចនូវភាសានៃម៉ែឪខ្លួនវិញទេតើ ៗ

ចំពោះយើងវិញ យើងយល់ថា បើយើងរកមធ្យោបាយធ្វើឲ្យការសិក្សាភាសាបារាំងមានសេចក្ដីចំរើនពុំបានទេ គប្បីយើងឈរលើផ្លូវសព្វថ្ងៃនេះសិនចុះ ចាំទំរាំយើងដោះស្រាយនូវបញ្ហាមួយដែលធំចំបងជាងបញ្ហាភាសាបារាំងនេះរួចសិន សឹមយើងលៃលកគតទៅទៀត—ដូចជាការបង្កើតនូវ វិទ្យាស្ថានពិសេសសំរាប់សិក្សាភាសាបរទេសសុទ្ធសាធជាដើម ៗ ពីព្រោះនៅពេលនេះ គឺ " បញ្ហាខេមរនីយកម្ម " ទេតើ ដែលឋិតនៅចំពីមុខយើងយ៉ាងជិតបំផុត ៗ ចាំអីយើង! ម្ដេចក៏មិននាំគ្នាហុចដៃទៅឈោងចាប់យក "ខេមរនីយកម្ម" នេះមក? —ទៅ! យើងនាំគ្នាដើរទៅមុខ!

★

តើយើងទាំងអស់គ្នាជាសាសន៍បារាំង ឬ?

— ប្រាកដជាពុំមែនទេ!

តើយុវជនខ្មែរ និង ប្រជារាស្ត្រខ្មែរទូទៅនិយាយភាសាបារាំង ជំនួសភាសាខ្មែរ ឬ?

— ប្រាកដជាពុំមែនទេ!

ពីព្រោះ យុវជនខ្មែរ និងប្រជារាស្ត្រខ្មែររស់នៅក្នុងកម្ពុជាពុំមែននៅហ្វ្រង្សទេ ៗ បានសេចក្ដីថា យុវជនខ្មែរ ប្រជារាស្ត្រខ្មែរ នៅក្នុងប្រទេសខ្មែរ និយាយទាក់ទងគ្នាទៅវិញទៅមកកល់ពេលកល់វេលា គ្រប់កាលៈទេសៈ តែជាភាសាខ្មែរ ហើយធ្វើការបំរើតែខ្មែរគ្នាឯងទេ ពុំមែនបំរើយុវជន ប្រជារាស្ត្របារាំងឯណា ៗ បើអញ្ចឹង ម្ដេចក៏នាំគ្នាភ័យអ៊ឹកភ័យម្ល៉េះ អំពីការដែលក្មេងខ្មែរចុះខ្សោយខាងភាសាបារាំងនៅប្រទេសខ្មែរ? បើតាមពិតយើងមិនត្រូវបារម្ភសោះចំពោះបញ្ហានេះ ព្រោះគឺជាបញ្ហាបន្ទាប់បន្សំតូចមួយសោះ ៗ នៅ

ក្នុងលោកទាំងមូលនេះគ្រប់ប្រទេសឯករាជទាំងអស់ (ប្រទេសដែលពិតប្រាកដជាឯករាជ្យ) មាតុភាសា បានត្រូវទទួលថ្នាក់លេខមួយ រីឯជីវភាសាបរទេសមានតំរិតត្រឹមថ្នាក់បន្ទាប់តែប៉ុណ្ណោះ ។ បើអញ្ចឹងនៅកម្ពុជាដែលជាប្រទេសឯករាជ្យយ៉ាងពិតប្រាកដ បញ្ហាក្មេងខ្មែរចុះខ្សោយខាងភាសាបារាំង ក៏ពុំមែនជាបញ្ហាធំដុំសំរាប់យើងដែរ – ទោះបីបើធំដុំវិញ ក៏ធំចំពោះតែជនខ្មែរមួយភាគតូចក្រៃលែង មិនទាំងដល់មួយចំបតូចផង ដែលអាចមានលទ្ធភាពបន្តការសិក្សារបស់ខ្លួន ខាងភាសាបារាំងនេះ តែប៉ុណ្ណោះ ។ ដូចនេះបញ្ហា « ខេមរនីយកម្ម » ក្នុងរបបសិក្សា ( បឋមសិក្សា និង មធ្យមសិក្សា ) ជាបញ្ហាជាតិពិតប្រាកដ ហើយជាបញ្ហាធំចំបងជាងបញ្ហា " បារាំងនីយកម្ម " ថែមទៀតផង ។

ចុះម្ដេចក៏មានលោកខ្លះ និយមទុកតម្លៃភាសាបារាំងថាខ្ពង់ខ្ពស់ប្រសើរជាងភាសាខ្មែរទៅវិញ? ចុះម្ដេចក៏មានលោកខ្លះយល់ថា ពាល់តែចេះភាសាបារាំងស្ទាត់ទើបយុវជនខ្មែរដែលរស់នៅក្នុងប្រទេសខ្មែរ មានតម្លៃថ្លៃថ្នូរ? យើងយល់ស្របទាំងស្រុងថា ការចេះភាសាបរទេស ពុំមែនឥតប្រយោជន៍ទេ... តែបើយើងចង់ចេះភាសាបរទេសនោះ យើងគប្បីបង្កើតវិទ្យាស្ថានពិសេសសំរាប់តែរៀនភាសាបរទេសទៅ ហើយនៅក្នុងមធ្យមសិក្សាយើងវិញ ភាសាបរទេស យើងគ្រាន់តែសិក្សាជាលំនាំៗ កុំឲ្យតែវង់ងឹតងងុលពេកតែប៉ុណ្ណោះ ក៏គ្រប់គ្រាន់ណាស់ទៅហើយ ។ រីឯវិទ្យាស្ថានសិក្សាភាសាបរទេសនោះ គឺសំរាប់អប់រំអ្នកចង់ធ្វើខ្លួន ឲ្យទៅជាអ្នកបកប្រែភាសា អ្នកកាសែត អ្នកធ្វើយថ្នូងទាក់ទងនិងបរទេស ឬ អគ្គទូតទៅចុះ ។ ចំពោះអ្នកភាគច្រើនដែលសិក្សាសំរាប់បំរើស្រុកខ្មែរផ្ទាល់ក្នុងស្រុកខ្មែរ សំរាប់កសិករខ្មែរ សំរាប់ពលរដ្ឋខ្មែរផ្ទាល់ក្នុងស្រុក គប្បីចេះភាសាជាតិឱ្យច្បាស់លាស់ទើបប្រសើរ ។ នេះជាយោបល់យើង ។

★

យើងសង្កេតឃើញថា សព្វថ្ងៃនេះ ជនរួមជាតិយើងមួយចំនួនបានប្រមូលអារម្មណ៍របស់ខ្លួន ទៅដាក់តែលើរឿងកូនខ្មែរខ្វាយបារាំង ៗ គេជាប់ចិត្តតែទៅលើភាសានឹងអក្សរបារាំង ៗ ទោះក្នុងការនិយាយស្តីក្តី ការសរសេរក្តី គេនឹកឃើញនឹងប្រើប្រាស់តែភាសាអក្សរបារាំង ជាជាងភាសាជាតិរបស់ខ្លួន ៗ ហេតុនេះហើយ បានជាក្នុងប្រកាសសារាចរ ដំណឹងដំណួចបន្តិចបន្តួច ឬក្នុងសំណុំលិខិត ពាក្យសុំប្រឡងចូលថ្នាក់ទី ៦ ឬក៏ពាក្យសុំប្រឡងសញ្ញាប័ត្រនានា ក៏គេនិយមប្រើតែភាសា អក្សរបារាំងដែរ ៗ

ទំលាប់និយមប្រើប្រាស់ភាសាអក្សរបារាំង ដែលមានមកហើយយ៉ាងនេះ នាំឲ្យគេក្លាយទៅជាខ្មែរម្នាក់ដែលខ្វាយខ្មែរស្រាប់ កាន់តែខ្វាយទៅៗ ហើយការនិយមបែបនេះ អាចនាំឲ្យជនខ្លះទៀត មានសេចក្តីខ្មាសអៀនដ៏ធំនឹងប្រើប្រាស់ភាសា អក្សរជាតិ ដែលមហាជន រាស្ត្រប្រជាស្តាប់បាន យល់បានគ្រប់ៗគ្នា... ប្រហែលមកពីគេយល់ថា ការប្រើប្រាស់ភាសា អក្សរជាតិនេះ ពុំបានធ្វើឲ្យគេប្លែកអ្វី អស្ចារ្យអ្វីបន្តិច អំពីមហាជនទាំងនោះសោះក៏មិនដឹង ?

ម្យ៉ាងទៀត ការពុំនិយមប្រើប្រាស់ភាសា អក្សរជាតិ នាំឲ្យគេពុំចេះពាក្យខ្មែរបានច្រើន- ជាហេតុនាំឲ្យកើតតមកទៀត នូវពាក្យពោលបង្អាប់ផ្សេងៗ ដូចជាថា : “ភាសាខ្មែរខ្វះពាក្យសំរាប់សំដែងសេចតនាឲ្យបានច្បាស់ បានចំ” ឬក៏ថា : “ភាសាខ្មែរខ្វះពាក្យតិចនិច ពាក្យស្យ្រង” ជាដើម ៗ

ជាការពិតមែនហើយដែលថា ភាសាខ្មែរពុំទាន់សំបូរពាក្យតិចនិច ពាក្យស្យ្រង ដូចជាភាសារបស់លោករូស្ស៊ូ លោកហ៊ុយហ្គោ តែវាក៏ជាការពិតផងដែរ ដែលថា ភាសាខ្មែរមានពាក្យយ៉ាងច្រើន នឹងមានរបៀបបង្កើតពាក្យ មានវេយ្យាករណ៍យ៉ាងល្អវិសេស ដែលជនខ្លះនៅពុំទាន់ចេះ នឹងពុំទាន់បានក្រេបរសជាតិ ដ៏ឈ្ងុយឆ្ងាញ់នេះ បាននៅឡើយ ៗ

ប៉ុន្តែ ប្រសិនបើយើងនិយមជាតិមែន យើងពុំត្រូវរវល់តែយកលេស “ ខ្វះពាក្យ ” ឬ “ ខ្វះសៀវភៅ ” មកប្រើ ដើម្បីអះអាងថា កុំអាលអនុវត្តខេមរនីយកម្ម ហើយក្នុងពេល

ដដែលនេះ ស្រាប់តែបែរទៅជារវល់នឹងគិតភ័យពីរឿងកូនខ្មែរ ចុះខ្សោយភាសាបារាំងទៅវិញនោះសោះ ។ អាកប្បកិរិយាទាំងពីរខាងលើនេះ មានទំនាស់នឹងគ្នា ហើយទាមទារឲ្យអ្នកម្ចាស់អាកប្បកិរិយាយកវាទៅពិនិត្យមើលខ្លួនឯងម្តងទៀត ។

ចំពោះយើងវិញ យើងយល់ថាត្រូវទុករឿងពូកែ ឬខ្សោយបារាំងមួយកន្លែងសិន ហើយត្រូវចាប់យករឿងខេមរនីយកម្មឲ្យពេញដៃ ពេញជើង មកពិនិត្យដោះស្រាយ ដើម្បីធ្វើឲ្យការសិក្សាជាតិ មានលក្ខណៈជាតិ មានប្រសិទ្ធិភាព មានមនុញ្ញផលច្រើន ហើយដើម្បីឲ្យស្របតាមព្រះរាជនយោបាយដ៏ខ្ពង់ខ្ពស់ "ជួយខ្លួនដោយខ្លួនឯង" នៃសម្តេចឪយើង ។ ក៏ប៉ុន្តែ ដើម្បីឲ្យខេមរនីយកម្មក្នុងរបបសិក្សាមានដំណើរទៅស្រួលនោះ យើងត្រូវតែធ្វើខេមរនីយកម្មក្នុងក្រសួងរាជការផងដែរ ។ រីឯខេមរនីយកម្មក្នុងក្រសួងរាជការ គឺជាការងាយបំផុត ៖ គឺគ្រាន់តែភ្នាក់ងាររាជការខ្មែរ ដែលទាក់ទងនឹងខ្មែរ ព្រមនិយាយខ្មែរ ព្រមសរសេរគ្រប់សំបុត្រស្នាម (ប្រកាស ដំណឹង សារាចរ...) ដែលសំរាប់ខ្មែរ ជាភាសាខ្មែរទៅ វាស្រេចគ្នាទៅហើយ ។

★

គួរឲ្យស្រពោនចិត្តណាស់ ដោយយើងឃើញនឹងភ្នែកថា ខ្មែរយើងភាគខ្លះលង់ខ្លួនផុងក្នុងរណ្តៅដំណោះ អំពីភាសាបារាំង នៅក្នុងស្រុកខ្មែរ ។ ចុះម្តេចក៏សាសន៍បារាំង គេពុំឈ្លោះគ្នាបង្កជាសង្គ្រាមប៉ាកាអំពីបញ្ហាក្មេងបារាំងចុះខ្សោយខាងអង់គ្លេស ខាងអេស្ប៉ាញ៉ុល ខាងអាល្លឺម៉ង់ ខាងរុស្ស៊ី... នៅឯស្រុកបារាំងដូចខ្មែរយើងដដែកគ្នាអំពីភាសាបារាំងនៅកម្ពុជាផង? (1)

ក្នុងការសិក្សាសព្វថ្ងៃ យើងពុំមែនសិក្សាតែអំពីភាសាបារាំងប៉ុណ្ណេះទេ ។ យើងត្រូវសិក្សាគ្រប់មុខវិជ្ជាទាំងអស់ រាប់ទាំងវិជ្ជាស្យង់ទូទៅ មនុស្សវិទ្យាទូទៅ រហូតដល់

(1)- យើងបានឮសាស្ត្រាចារ្យបារាំងម្នាក់ពោលថា ខ្លួនលោកសព្វថ្ងៃនេះ មានការខ្វះខាងភាសាអង់គ្លេសតិចជាងយើង ដែលមានការខ្វះខាងភាសាបារាំងផង ។ យើងសូមបញ្ជាក់ថា សាស្ត្រាចារ្យជាតិបារាំងនោះមានកំរិតវិជ្ជាខ្ពង់ខ្ពស់ណាស់ ។

កសិកម្មវិទ្យា ហត្ថកម្មវិទ្យា កីឡា សិល្បៈ ហើយជាពិសេស គឺវិជ្ជាយល់ច្បាស់គ្រប់មែកធាង គ្រប់វិស័យ ដើម្បីទាញយកពុទ្ធិ ខាងករណីយកិច្ចពលរដ្ឋថ្ថូរ ស្នេហាវឌ្ឍនភាពពុំអាក់នៃសង្គមខ្មែរទាំងមូល ។

មានលោកសាស្ត្រាចារ្យជាច្រើនបានពោលថា "ពិបាកបង្រៀននូវមុខវិជ្ជាផ្សេងៗ ដល់កូនខ្មែរណាស់ ពីព្រោះក្មេងឥឡូវខ្សោយបារាំងណាស់ – បើបានបង្រៀនជាខ្មែរនោះ សមស្រួលណាស់" ។ សូមអញ្ជើញស្ដាប់និងគិតនូវសំដីនេះផងចុះ ។ យើងឃើញថា ឧបសគ្គមួយយ៉ាងធំ បានងើបឡើងពាំងផ្លូវសិស្សខ្មែរយើង មិនឲ្យឈោងចាប់យកវិជ្ជាផ្សេងៗបានងាយស្រួលសោះ –ទោះបីបើបានខ្លះៗ ក៏បានទាំងត្រដាបត្រដួសដែរ ពីព្រោះគ្រូបូរហ៊ុសទៅហើយ ចុះទំពាំក្នាជាសិស្សទៀត យ៉ាងម្ដេចទៅដែរ? – ឧបសគ្គនោះ គឺ ការយកភាសាបារាំង ជាភាសាយានជេះឯង ។

ដូចនេះ ដើម្បីឲ្យសិស្សខ្មែរអាចចូលទៅរកពុទ្ធិ ក្នុងគ្រប់មុខវិជ្ជាដែលខ្លួនត្រូវសិក្សាបានងាយនោះ ខេមរនីយកម្ម ក្នុងបឋសិក្សា ( មធ្យមសិក្សា និង បឋមសិក្សា ) គឺជាការចាំបាច់ ពីព្រោះកូនខ្មែរនិយាយខ្មែរតាំងពីកើតមក ស្រួលចំណាំ ស្រួលកត់ត្រា នូវអ្វីៗទាំងអស់ដែលគេបង្ហាញ បង្រៀននិងពន្យល់ជាភាសាខ្មែរ ។

សូមកុំយល់ដោយស្មានទិនដោយប្រឡំឲ្យសោះថា ខ្មែរខ្វះពាក្យប្រើ សំរាប់វិទ្យាស្យង្ស និងសំរាប់មនុស្សវិទ្យា ។ ភស្តុតាងយ៉ាងជាក់ស្ដែងមានដូចតទៅ ៖

– ខាងផ្នែកច្បាប់ សារពត៌មាន "អ្នកជាតិនិយម" បានចេញអត្ថបទជាខ្មែររាល់ៗលេខស្ដីអំពីច្បាប់ក្រមព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី... ។

– ខាងផ្នែកវិជ្ជាពេទ្យ វិទ្យុសំលេងកម្ពុជាបានផ្សាយ នាទីក្រសួងសាធារណសុខាភិបាលរាល់ល្ងាចថ្ងៃពុធ និងរាល់ល្ងាចថ្ងៃសៅរ៍ជាភាសាខ្មែរ ។

– ខាងផ្នែកគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា... ពុទ្ធិកមហាវិទ្យាល័យបានបង្ហាត់បង្រៀនព្រះសង្ឃខ្មែរជាភាសាខ្មែរបានរួចទៅហើយ ។

– ខាងមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្របានលើកយកមុខវិជ្ជាពិបាកមួយមុខ ដែលប្រើពាក្យយ៉ាងទៀងទាត់បំផុត មកបង្រៀនជាភាសាខ្មែរ បានយ៉ាងស្រួលទៅហើយដែរ ។ មុខវិជ្ជានេះ គឺទស្សនវិជ្ជា ។

– ខាងផ្នែកនយោបាយ សម្ដេចឪជាទីគោរពរបស់យើង ក៏ទ្រង់បានថ្លែងនូវសុន្ទរកថាជាភាសាខ្មែរបានយ៉ាងស្រួលបំផុត ។

ដូចនេះ ពាក្យថា ខ្មែរខ្វះពាក្យប្រើ គឺជាការពុំពិតសោះ ។

ខ្មែរខ្វះពាក្យប្រើ គឺមកតែពីខ្មែរពុំព្រមប្រើភាសាខ្មែរតែប៉ុណ្ណោះ ។ បើខ្មែរព្រមប្រើភាសាខ្មែរនោះ ខ្មែរពុំខ្វះពាក្យខ្មែរសំរាប់ប្រើជាដាច់ខាត ។ បើអញ្ចឹង ខេមរនីយកម្ម ក្នុងរបបសិក្សាក្ដី ក្នុងក្រសួងរាជការក្ដី ពុំត្រូវទៅពុំរួចសោះជាដាច់ខាត ។ ឲ្យតែយើងយល់ព្រមធ្វើខេមរនីយកម្ម គឺយើងធ្វើកើតជាដាច់ខាត ។

យើងពុំត្រូវក្វេចមាត្រា ២ នៃរដ្ឋធម្មនុញ្ញទេ ! យើងត្រូវអនុវត្តនូវមាត្រានេះ ឲ្យបានពេញលេញ ។ កុំបណ្ដោយឲ្យសំដីនៃរដ្ឋធម្មនុញ្ញមាននៅតែក្នុងសៀវភៅអញ្ចឹង ។

ប្រទេសខ្មែរបានឯករាជ្យរឹងប៉ឹងហើយ ! វប្បធម៌ខ្មែរក៏ត្រូវតែបានឯករាជ្យពេញលេញនឹងរឹងប៉ឹងដែរ ! ចុះចាំកាលណា ទើបយើងផ្ដល់នូវឯករាជ្យពេញលេញ រឹងប៉ឹង (ពិតប្រាកដ) ដល់ភាសាខ្មែរ ?

ត្រូវបំបាត់ « ហ្វ្រង់សេយកម្ម » ចេញទៅ !

ត្រូវតែធ្វើឲ្យខេមរនីយកម្ម បានសំរេចជ័យជំនះឡើង បើយើងពិតជាខ្មែរ !

★ ★ ★

# ខេមរនីយកម្មនៃការសិក្សា

អ៊ុក សាម៉ន

មហាវិទ្យាល័យ សិល្បៈ និងមុខរបរ

ក្រោយ ពីបានអានទស្សនាវដ្ដីសាស្ត្រាចារ្យខ្មែរ លេខ ២៣ ក្រោមចំណងជើង: "យោបល់លោកនាយកមធ្យមសិក្សា ចំពោះបញ្ហាខេមរនីយកម្ម" ខ្ញុំមានសេចក្ដីរីករាយជាពន់ពេកណាស់ ព្រោះគឺជាបញ្ហាដែលខ្ញុំបានយកចិត្តទុកដាក់ ចាប់អារម្មណ៍ទៅលើជាយូរយារណាស់មកហើយ ហើយដែលមជ្ឈដ្ឋានសំខាន់នានានៃសង្គមជាតិយើង មានមជ្ឈដ្ឋានអ្នកអប់រំជាតិជាទូទៅ និងមជ្ឈដ្ឋានសាស្ត្រាចារ្យយើងជាពិសេស ក៏បានលើកយកបញ្ហាខេមរនីយកម្មនេះ មកចោទនិងដោះស្រាយជាច្រើនលើកច្រើនគ្រាមកហើយដែរ ។

រីឯខ្លួនខ្ញុំ ពិតមែនតែថា ខ្ញុំជាសាស្ត្រាចារ្យ ១ រូបនិងគេដែរ ហើយជាពិសេសជាសាស្ត្រាចារ្យខាងអក្សរសាស្ត្រខ្មែរថែមទៀតផង ហើយពិតមែនតែថា ខ្ញុំបានយកចិត្តទុកដាក់ចាប់អារម្មណ៍ទៅលើបញ្ហានេះខ្លាំងណាស់ដែរផងក៏ដោយ ក៏ខ្ញុំនៅមានគំនិត ១ យល់ឃើញថា "កុំបោះសន្ទូចរំលងក្ន" ឬ "កុំទុំមុនស្រគាល" ឬ ១ ទៀត "កុំលឿនជាងចន្ទោល" យ៉ាងនេះជាដពប ។ ដូចនេះ ក្រៅតែអំពីមានតែចិត្តចង់នឹងការបញ្ចេញនូវចំណង់ចិត្តទាំងនេះ ទៅតាមទីកន្លែងដែលគួរ ដែលអាច គឺខ្ញុំពុំទាន់បានធ្វើអ្វីទាល់តែសោះ ។

ឥឡូវនេះ ឱកាសដែលខ្ញុំរង់ចាំយូរមកហើយបានមកដល់ គឺឱកាសដែលបានឃើញថា នាយចៅហ្វាយផ្ទាល់របស់ខ្ញុំ គឺលោកនាយកមធ្យមសិក្សា លោកក៏មានមតិគំនិតយោបល់ ចំពោះបញ្ហាខេមរនីយកម្មនេះ ស្របស្រួលត្រូវទៅតាមបំណូលចំណង់ចិត្តរបស់ខ្ញុំនិងរបស់មិត្តដទៃទៀតភាគច្រើនដែរ ។ ដូចនេះ ខ្ញុំក៏សូមកងឱកាសនេះ បញ្ចេញនូវមតិយោបល់របស់ខ្ញុំខ្លះៗ ចំពោះបញ្ហាខាងលើនេះ ដែលតាមពិតពុំមែនជាមតិគំនិតអ្វីថ្មីប្លែកទេ

ប៉ុន្តែ គឺគ្រាន់តែជាមតិគំនិតសំរាប់បំពេញ សំរាប់បញ្ជាក់សង្កត់បន្ថែមទៅលើ តែប៉ុណ្ណោះ ព្រោះថា គោលគំនិតធំៗសំខាន់ៗទាំងប៉ុន្មាន ចំពោះខេមរនីយកម្មនេះ លោកនាយកមធ្យមសិក្សា លោកបានលាតត្រដាងបង្ហាញបំភ្លឺសព្វគ្រប់រួចអស់មកហើយ ។

ម្យ៉ាងទៀត ហេតុដែលនាំឲ្យខ្ញុំ ហ៊ានបញ្ចេញនូវសំលេងរបស់ខ្ញុំ ក្នុងពេលនេះទៀត ក៏មកពីថាកាលសមាជជាតិលើកទី ២២ កន្លងទៅនេះ លោកស្រីរដ្ឋលេខាធិការក្រសួងអប់រំជាតិ បានមានសេចក្ដីក្លាហានហ៊ានបញ្ជាក់ប្រាប់សមាជថា សព្វថ្ងៃមានទិន្នាការ ១ យ៉ាងខ្លាំងឆ្ពោះទៅរកខេមរនីយកម្មនៃការសិក្សា ។

ការដែលព្រមដឹងឮ ព្រមទទួលស្គាល់ថាមានទិន្នាការ ១ ចំពោះខេមរនីយកម្មយ៉ាងនេះ ក៏អាចចាត់ទុកបានថាជាជំនួយ ១ យ៉ាងធំ ចំពោះចលនាខេមរនីយកម្មនេះដែរ ព្រោះថា ពីមុនៗមក គេពុំសូវដែលបានឮសំដីដ៏ច្បាស់លាស់ប្រាកដនិយមបែបនេះទេ គេច្រើនតែឮពាក្យថា « កូនសិស្សខ្មែរសព្វថ្ងៃរៀនអន់ណាស់ » « កូនខ្មែរខ្សោយបារាំងណាស់ » ឬ ឮថា « Méthode នេះ រៀនបារាំងមិនចំរើនទេ, Méthode នោះ ទើបប្រសើរជាង » ពុំនោះសោតឮតែថា «ការបំបាត់ភាសាបារាំងជាការ ធ្វើហួសវិស័យ ព្រោះភាសាបារាំងគឺជាភ្នែក ជាច្រមុះ ជាត្រចៀក ជាបង្អួច ... ។ល។ និង ។ល។ »

ប៉ុន្តែ ពាក្យពោលទាំងប៉ុន្មានខាងលើនេះ សុទ្ធតែចាកប្រធានទាំងអស់ ! — តើមាននរណា ១ ថាចង់ឲ្យកូនខ្មែរឈប់រៀនភាសាបារាំង ?

ខ្ញុំសូមពុំធ្វើអត្ថាធិប្បាយអំពីរឿង « ចាកប្រធាន » ខាងលើនេះទេ ព្រោះថាបើពិតជាមានសុធម្មៈមែន គេពុំអាចយល់ច្រឡំទៅកើតអំពីពាក្យថា « ភាសាយាន » langue véhicule និង « ជីវភាសា » langue vivante នោះទេ ។

បញ្ហាពិតនៅត្រង់ថា តើក្នុងសម័យដែលប្រទេសយើងបានឯករាជ្យពេញលេញហើយនោះ យើងគួរតែលើកតំកើងភាសាជាតិយើងឲ្យមានមុខមាត់ មានរស្មីបញ្ចេញចិញ្ចែងស្មើឋានៈ ស្មើភាពនិងគេឯង ឲ្យសមឋានៈខ្លួនជាជាតិឯករាជ ជាភាសាឯករាជ

មានតំលៃគ្រប់គ្រាន់ មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការយល់និងពន្យល់ដែរឬទេ ? ឬមួយក៏យើងត្រូវតែប្រើភាសាបរទេស គឺភាសាបារាំងនេះតទៅទៀត លើកតំកុំតំកើងឲ្យតំលៃទៅលើភាសាបារាំងដែលជាបរទេសនេះតទៅទៀត ? ( ខ្ញុំនិយាយនេះ មិនចំពោះតែរឿងសិក្សារៀននិងបង្រៀនប៉ុណ្ណោះទេ គឺនិយាយចំពោះការប្រើភាសាជាតិជាទូទៅ តាមគោលគំនិតរដ្ឋធម្មនុញ្ញ ) ។

ប្រសិនបើយើងយកតាមមូលភាព ( principe ) ទី២ ពោលគឺការឲ្យតំលៃតទៅទៀតចំពោះភាសាបារាំងនោះ ក៏គួរតែយើងខំប្រឹងប្រែងខាងបារាំងនោះឲ្យខ្លាំងតទៅទៀត រកវិធីរកមធ្យោបាយឲ្យអស់ដៃអស់ជើង គាស់គាយយ៉ាងណាឲ្យខាងតែកូនសិស្សខ្មែរ ជាង ១ លាននាក់នេះ "ពូកែបារាំង" ហើយរៀនបានចំរើនដឿនលឿនទៅមុខទៀតទៅ ! ។

ប៉ុន្តែ ផ្ទុយទៅវិញ ប្រសិនបើយើងយល់ថាទេ ខ្មែរឯករាជហើយ ពិតមែនតែខ្មែរត្រូវតែចេះភាសាបរទេស ទោះបីបារាំងក៏ដោយ រុស្ស៊ីក៏ដោយ អង់គ្លេសក៏ដោយ ។ល។ ខ្មែរត្រូវតែលើកតំកើងភាសាជាតិរបស់ខ្លួន ខ្មែរត្រូវតែខំសំអិតសំអាងភាសាជាតិខ្លួនបញ្ចេញមុខមាត់លើកតំកុំតំកើងប្រមែប្រមុំឲ្យមានជារូបរាង ជាចលនាសកម្មភាពឡើងនោះ ពេលនោះ យើងត្រូវតែដើរទៅមុខចំពោះបញ្ហានេះ ទោះបីមានឧបសគ្គការលំបាកយ៉ាងណាក៏ដោយ ។

ដូចលោកនាយកមធ្យមសិក្សា បានមានប្រសាសន៍ស្រាប់ ការអ្វីដែលធ្វើតែងតែលំបាកហើយជាពិសេស អ្វីដែលលំបាក គឺអ្វីដែលថ្មីនោះឯង ។ ប៉ុន្តែបើយើងខ្លាចលំបាកពុំព្រមហ៊ានពុះពារបន្តិចម្តង ៗ ធ្វើម៉េចយើងនឹងទៅដល់គោលដៅ ? យើងបានឯករាជ្យមកចំនួន ១៤ ឆ្នាំហើយ រដ្ឋធម្មនុញ្ញមានមកចំនួន ២០ ឆ្នាំមកហើយ ! តើភាសា-អក្សរ-អក្សរសាស្ត្រជាតិយើង បានដើរដល់ណាហើយ ? ដល់ «ប៉ុយរ៉ូ» ណាខ្លះហើយ ? ដល់សាលាណាខ្លះហើយ ? ដល់ផ្សារចាស់ ? ផ្សារថ្មី ? ឬមួយក៏នៅតែក្នុងវត្ត និងនៅស្រុកស្រែចំការនៅឡើយទេ ? ប៉ុន្តែ អ្នកវិទ្យាសាស្ត្រវិញ គេទៅដល់លោកខែហើយ ! . . . ។

សព្វថ្ងៃនេះ ការមិនដើរទៅមុខពុំមែនបានសេចក្ដីថា នៅនឹង ១ កន្លែងនោះទេ ប៉ុន្តែ គឺដើរថយក្រោយ ព្រោះថាផែនដីចេះតែវិលទៅមុខជានិច្ច ធម្មជាតិចេះតែមានវិវត្តផ្លាស់ប្ដូរជាធម្មតា ។ ហើយដូចលោកនាយកមជ្ឈមសិក្សាក៏បានមានប្រសាសន៍ស្រាប់ថា «ការដោះស្រាយបញ្ហាខេមរនីយកម្មក្នុងពេលនេះ មានភាពហួសពីការសមរម្យទៅទៀត» ។ ដូចនេះ យើងនៅការង់ដល់ណាទៀត? ខ្លាចមាន "កោលាហល់" ដូចម្ដេច? យើងធ្វើតែតាមប្រយោជន៍ជាតិ ធ្វើតែតាមសេចក្ដីត្រូវការ ធ្វើតែតាមការចាំបាច់ ធ្វើតែតាមព្រះច្បាប់ (រដ្ឋធម្មនុញ្ញ) ។

មតិយោបល់របស់ខ្ញុំទាំងនោះ សូមបង្រួមក្នុងបញ្ហាចោទសួរទាំង ៤ ខ ដូចតទៅ ៖

## I– តើភាសាបារាំងពិតជាភាសាយាន សំរាប់យុវជនខ្មែរមែន ឬទេ?

១– មាត្រា ២ នៃរដ្ឋធម្មនុញ្ញចែងថា: "ភាសាដែលប្រើជាផ្លូវការ គឺភាសាខ្មែរ" ។ ដូចនេះ អ្វីដែលជាផ្លូវការមានការសិក្សា រៀន និង បង្រៀននេះជាដើម ត្រូវតែគោរពទៅតាមមាត្រា ២ នៃរដ្ឋធម្មនុញ្ញខាងលើនេះ ។

២– កាលជំនាន់មុន យើងទុកភាសាបារាំងជាភាសាយាន (langue véhicule) ព្រោះថាប្រទេសយើងមុនបានឯករាជ្យ យើងធ្លាប់មានការទាក់ទងជាមួយប្រទេសបារាំងរួចស្រេចទៅហើយ ។ ក្រោយដែលយើងបានឯករាជ្យមក យើងត្រូវការបំណេះវិជ្ជាខ្ពស់ៗ តិចនិច វិទ្យាសាស្ត្រ អ្នកបច្ចេកទេស វិស្វករ ដើម្បីកសាងស្ថាបនាប្រទេសយើងឲ្យបានទៅជាអរិយប្រទេសទាន់កាលសម័យនឹងគេ ។ ហើយជាជាងយើងធ្លាប់មានការទាក់ទងជាមួយបារាំងស្រាប់ទៅហើយ យើងក៏បានសំរេចថា យកប្រទេសបារាំងជា "ថ្នាល" សំរាប់សាបព្រួសបណ្ដុះនូវវិជ្ជាខ្ពស់ៗ តិចនិច វិទ្យាសាស្ត្រ អ្នកបច្ចេកទេស និង វិស្វករទាំងនោះ ។ ដូចនេះ ការចេះភាសាបារាំងជាការចាំបាច់ ពីព្រោះយើងទៅសុំរៀនពីគេនៅប្រទេសគេ ។ ប៉ុន្តែ

៣– និស្សិតខ្មែរយើង តាមការពិតទៅ ពុំមែនទៅរៀនក្រេបជញ្ជក់ចំណេះវិជ្ជាគ្រប់បែបគ្រប់យ៉ាងទាំងនោះ ដើម្បីមកកសាងប្រទេសរបស់ខ្លួន តែអំពីប្រទេសបារាំង ១ ពីកាលណា ? គឺយើងទៅរៀនស្ទើរតែទៅគ្រប់ប្រទេសជាមិត្តទាំងអស់ ដែលគេប្រើភាសារបស់គេរៀង ៗ ខ្លួនក្នុងការបង្ហាត់បង្រៀននិស្សិតយើង ៗ ម្យ៉ាងទៀត

៤– ក្រោមព្រះបញ្ញាញាណដ៏ភ្លឺស្វាងនៃសម្តេចឪ របស់យើង យើងបានបង្កើតមហាវិទ្យាល័យយ៉ាងសន្ធឹកសន្ធាប់នៅស្រុកយើង ដែលមានមុខវិជ្ជាស្ទើរតែគ្រប់សព្វមែកធាងទាំងអស់ទៅហើយ ៗ តើយើងមានប្រយោជន៍អ្វីនឹងបញ្ជូននិស្សិតយើងទៅរៀននៅបរទេស ជាពិសេសនៅប្រទេសបារាំងធ្វើអ្វីទៀត ?

ប៉ុន្តែត្រង់កន្លែងនេះ គេអាចឆ្លើយមកវិញថា ពិតមែនតែយើងមានមហាវិទ្យាល័យគ្រប់បែបយ៉ាងនៅស្រុកយើង ប៉ុន្តែអ្នកបង្រៀនមិនមែនជាតិខ្មែរទេ (ភាគច្រើន) ៗ – បាទស្តាប់បាន ប៉ុន្តែពាក្យចាស់លោកពោលថា "ចេះមកពីរៀន មានមកពីរក" ប្រសិនបើយើងខ្វះខាតនូវគ្រូជាតិខ្មែរសំរាប់បង្រៀនវិជ្ជាជាន់ខ្ពស់ៗ ទាំងនោះ យើងត្រូវតែរៀបចំជាផែនការយ៉ាងណា ដើម្បីបង្កើតឲ្យមានឡើងបន្តិចម្តងៗ គង់នឹងបានសំរេច តាមទំនងដូចដែលយើងបានធ្វើរួចមកហើយ ចំពោះសាស្ត្រាចារ្យមធ្យមសិក្សាសព្វថ្ងៃ ៗ ម្យ៉ាងវិញទៀត

៥– ភាសាបារាំង ក៏យើងពុំបានគិតទុកថា នឹងលុបបំបាត់ចោលនោះក៏ទេដែរ ផ្ទុយទៅវិញ យើងថាត្រូវតែរកវិធីណា មធ្យោបាយណា ដើម្បីបំពិន ពង្រឹងឲ្យកាន់តែប្រសើរឡើងទៀត ក្នុងឋានៈជា "ភាសារស់" បរទេសដូចគ្នា នឹងភាសាអង់គ្លេស រុស្ស៊ី, អេស្ប៉ាញ៉ុល, ចិនជាដើម ៗ ប៉ុន្តែចាំដល់ទៅថ្នាក់ធំៗ បន្តិចសិន (សុំកុំច្រឡំចំណេះខាងភាសា នឹងចំណេះខាងសាស្ត្រ នឹងគិតបនិច) ៗ

## II– តើភាសាបារាំង ពិតជាភាសាចាំបាច់ ចំពោះខ្មែរឯករាជសព្វថ្ងៃ ឬទេ ?

១– កាលយើងនៅក្រោមនឹមនៃអាណានិគមបារាំងនៅឡើយ ភាសាបារាំងជាការចាំបាច់ ព្រោះបារាំងត្រូវការនិយាយស្ដីជាមួយយើង ត្រូវការប្រើប្រាស់យើង ត្រូវការសាកសួរយើង ។ ដូចនេះ ទោះបីអ្នកឯងជារាស្ត្រសាមញ្ញ ជាកម្មករ កសិករ ជាប៉ុងតុង ចិចុង ស្មៀនស្មេរ គ្រូបង្រៀន ឬ ជាលោកអ្នក ឯកឧត្ដមក៏ដោយ ក៏ត្រូវតែចេះបារាំង ព្រោះលោក "ធំ" បារាំងដែលជា « ចៅហ្វាយ » លោកពុំចេះ ពុំយល់ភាសាខ្មែរដែលជា "បាវ" របស់គាត់នោះទេ ។

២– ផ្ទុយទៅវិញ សព្វថ្ងៃនេះប្រទេសយើងឯករាជហើយ អស់មានលោកធំ លោកតូចអ្វីទៀតហើយ គឺយើងមានតែខ្មែរគ្នាឯង ខ្មែរឯករាជ ខ្មែរសេរី ( មិនមែនអា "ខ្មែរសេរី" ខ្ញុំគេញដំណនោះទេ ! ) ខ្មែរដែលធ្លាប់មានកេរ្តិ៍ឈ្មោះពូជពង្សខ្ពង់ខ្ពស់ អរិយធម៌ធំទូលាយពីអតីតកាលនោះ ភាសាបារាំងហាក់ដូចជាពុំមានសារៈសំខាន់ចាំបាច់អ្វីប៉ុន្មានទេ ។ បើយើងជាខ្មែរទាក់ទងតែនឹងខ្មែរគ្នាឯងសុទ្ធសាធតែប៉ុណ្ណោះ ការប្រើភាសាខ្មែរកាន់គ្នាទៅវិញទៅមក ក៏ជាការប្រពៃណាស់ទៅហើយ ។

៣– ដូនតាយើង មានព្រះមហាវីរក្សត្រដ៏ឆ្នើមៗពីព្រេងនាយជាដើម ដែលលោកប្រើតែភាសាខ្មែរសុទ្ធៗ សំរាប់ទាក់ទងតែនឹងខ្មែរគ្នាឯងនោះ ក៏គង់លោកចេះកសាងបុរាណវត្ថុ មានប្រាសាទសិលាទានាទុកសំរាប់កិត្យានុភាព ក្នុងផ្ទៃពិភពអន្តរជាតិដល់កូនចៅលោកជំនាន់ក្រោយនេះបានដែរ ។

## III– តើភាសាបារាំង ពិតជានាំឲ្យខ្មែរមានតម្លៃជារដ្ឋឯករាជពេញលេញឬទេ?

ខ្ញុំសូមញែកបញ្ហានេះ ជា ៣ ផ្នែក ដូចតទៅ ៖

១– ពួកបញ្ញាវន្ត អ្នកនយោបាយ អ្នកបច្ចេកទេសធំៗ អ្នកគ្រប់គ្រង ពោលដោយខ្លី គឺអ្នកដែលមានភារៈដឹកនាំប្រទេសជាតិ ឆ្ពោះទៅមុខរកវឌ្ឍនភាព ( les élites du pays )

ត្រូវតែចេះភាសាបារាំងតិចច្រើនតាមមុខងារ តាមសមត្ថភាព សមត្ថកិច្ច ព្រោះអ្នកនោះតែងតែមានការទាក់ទងតិចច្រើន ជាមួយបរទេសជាធម្មតា ។ ប៉ុន្តែតើចំនួនអ្នកទាំងនោះមានប៉ុន្មាននាក់ បើធៀបទៅនឹងចំនួនប្រជាជនយើងប្រហែលជិត ៧ លាននាក់នោះ? ខ្ញុំថាមានប្រហែល ៧ ពាន់នាក់ទៅចុះ ។ ដូចនេះ គឺ ១/១០០០ ឃើញថាតិចតួចណាស់ ។ សល់ពីនោះ ប្រហែលជាមិនចាំបាច់ចេះបារាំងមួយម៉ាត់ផងក៏បានដែរមើលទៅ ។

២– ការប្រើភាសាបារាំងជាទូទៅ ក្នុងការរដ្ឋការក្តី ក្នុងការសិក្សាក្តី បើគ្រាន់តែប្រើជាបណ្តោះអាសន្ន ដូចយើងបានធ្វើរួចមកហើយនេះ ក៏ជាការសមរម្យម្យ៉ាងដែរ ។ ប៉ុន្តែបើចេះតែប្រើ ចេះតែនិយម ចេះតែឲ្យតម្លៃរហូតតទៅទៀត ខ្ញុំថាដូចជា ពុំមែនជាកិត្តិយសដល់ជាតិយើងទេ ព្រោះថា

៣– ប្រទេសឯករាជ្យ គឺជាប្រទេសដែលមានសមត្ថភាព មានលទ្ធភាពរស់ដោយខ្លួនឯង ពុំមែននៅក្រោមបង្គាប់បញ្ជានរណា ពុំនៅក្រោមការឧបត្ថម្ភទំនុកបំរុងរបស់ប្រទេសណា ឬ ពឹងពាក់អាស្រ័យ (dépendant) ទៅលើប្រទេសណាគ្រប់ផ្នែក គ្រប់វិស័យ ។

ប្រទេសយើង ក្រោមព្រះកិច្ចដឹកនាំដ៏វាងវៃនៃសម្តេចឪជាអម្ចាស់ យើងក៏បានឯករាជ្យពេញបរិបូណ៌គ្រប់ផ្នែកមែកធាងទាំងអស់ មានផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច តុលាការនិងវប្បធម៌ជាដើម តាំងពីឆ្នាំ ១៩៥៣ មក ។ ការដែលវប្បធម៌ជាតិយើង ពិសេសគឺផ្នែកភាសា -អក្សរនេះ នៅមានការពឹងពាក់ផ្អែកទៅលើគេនៅឡើយនោះ ក៏ជាការអាមាសមុខណាស់ទៅហើយ ប៉ុន្តែធ្វើម៉េច យើងទើបនឹងបានឯករាជ្យ យើងត្រូវតែអត់ធ្មត់សង្កត់ចិត្ត ពឹងផ្អែកទៅលើគេសិន ។ ប៉ុន្តែពេលនេះល្មមគ្រប់គ្រាន់ហើយ ១៤ ឆ្នាំកន្លងមកហើយ ល្មមយើងដោះខ្លួនឲ្យរួចអំពីការពឹងផ្អែកទៅលើគេទៀត ក្នុងផ្នែកភាសា-អក្សរនេះ ដើម្បីឲ្យឯករាជ្យជាតិរបស់យើងមានសភាពលក្ខណៈពេញលេញមែនទែនឡើង ព្រោះខ្មែរពុំមែនជាជាតិសាសន៍ដែលគ្មានភាសា-អក្សរ សំរាប់និយាយ-សរសេរនោះទេ ។

ផ្ទុយទៅវិញ ក្នុងបញ្ហានេះ ប្រសិនបើយើងពុំព្រមរើបំរះឲ្យរួចពីការពឹងផ្អែកទៅលើគេនោះ ឯករាជ្យជាតិខ្មែរយើងក៏ហាក់ដូចជាពុំទាន់អស់ " មន្ទិល " ( souillure ) នៅឡើយ ។ ព្រោះថា បើពិតជាឯករាជ្យមែន យើងតោងតែមានសិទ្ធិសេរីភាព សមភាព ស្មើនឹងប្រទេសឯករាជ្យដទៃទៀតដែរ ទោះអ្នកនោះ តូចក្តី ធំក្តី មិនចំពោះតែផ្លូវនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច –ល– ប៉ុណ្ណោះទេ ប៉ុន្តែវប្បធម៌ ជាពិសេសភាសា-អក្សរ ក៏តោងតែមានសមភាពស្មើនឹងគេដែរ ។ បានសេចក្តីថា បើយើងមានការចាំបាច់ត្រូវតែចេះភាសាគេ ដើម្បីទាក់ទងជាមួយនឹងគេ រីឯគេវិញ ក៏តោងតែមានការចាំបាច់ត្រូវតែចេះភាសាយើង ដើម្បីទាក់ទងជាមួយនឹងយើងវិញ ។ តួយ៉ាងដូចប្រទេសចិនប្រជាមានិត សហភាពសូវៀត សាធារណរដ្ឋប្រជាធិបតេយ្យ អាល្លឺម៉ង់ កូរ៉េខាងជើងជាដើម ដោយគេយល់ន័យច្បាស់ចំពោះ «ឯករាជ្យ» របស់ប្រទេសខ្មែរយើង គេក៏បានបញ្ជូននិស្សិតគេឲ្យមករៀនភាសាយើង នៅស្រុកយើង ហើយសុំឲ្យសាស្ត្រាចារ្យខ្មែរយើងទៅបង្រៀនភាសាយើងនៅប្រទេសគេថែមទៀត ។ យើងវិញក៏បានឆ្លើយតបការនេះ តាមទំនងដូចគ្នាដែរ គឺយើងបានបង្កើតវិជ្ជាដ្ឋាន ១ ក្នុងផ្ទៃនៃមហាវិទ្យាល័យអក្សរសាស្ត្រយើង សំរាប់បង្រៀនភាសាបរទេស មានភាសាចិន រុស្ស អាល្លឺម៉ង់ជាដើម ដោយសុំឲ្យសាស្ត្រាចារ្យគេមកបង្រៀន ។

ផ្ទុយទៅវិញ ចំពោះបារាំង ដែលយើងខំឈ្លោះប្រកែកគ្នា បង្អាប់បន្តុះគ្នា តែអំពីរឿងភាសាអក្សររបស់គេនោះ តើគេមានបាននឹកនា ឬ យល់សប្តិថា នឹងបង់ឲ្យនិស្សិតគេរៀនភាសាយើងទេ ទោះនៅស្រុកគេក្តី នៅក្នុងស្រុកយើងក្តី ? គ្មាន ! ព្រោះគេឃើញថា យើងនៅតែត្រូវការគេ នៅតែចង់ពឹងពាក់គេ នៅតែនិយម ស្រឡាញ់ឲ្យតំលៃទៅភាសាគេទៅឡើយ ( ភស្តុតាង មើលតែសកម្មភាពនឹងសភាពរីកចំរើននៃវិទ្យាល័យ Descartes របស់គេក្នុងប្រទេសយើងក៏ឃើញស្រាប់– ដូចនេះ ទោះបីគេត្រូវការចង់ពឹងពាក់

ទាក់ទងអ្វីដល់យើង ក៏គេពុំវល់ដល់ភាសាយើងដែរ ព្រោះយើងចេះភាសាគេ យើងនិយមប្រើភាសាគេស្រាប់ទៅហើយ – ស្រណុកមែន ! ( ត្រង់នេះ ពាក្យថា « ប្ដូរវប្បធម៌គ្នា » échange culturelle ហាក់ដូចពុំសូវមានន័យប៉ុន្មាន ) ។

## IV– តើការយកភាសាបារាំងជាយាន ជាគុណឬជាទោសចំពោះសិស្ស ?

បញ្ហានេះ មានការចោទនឹងដោះស្រាយ ជាច្រើនលើក ច្រើនគ្រាណាស់មកហើយ ហើយមតិគំនិតក៏ចេះតែបែកខ្ញែកគ្នាទៅទីទៃៗ ខ្លះថាជាគុណ ខ្លះថាជាទោស ។

នៅក្នុងទស្សនាវដ្ដីសាស្ត្រាចារ្យលេខ ២៣ មុននេះ លោកនាយកមធ្យមសិក្សាក៏បាន វែកញែកនូវបញ្ហានេះដ៏ក្បោះក្បាយ ល្មមជាការស្ដាប់បាន យល់បានរួចស្រេចហើយដែរ ដែលតាមយោបល់លោក លោកក៏យល់ថាជាទោសដែរ ខ្ញុំពុំបាច់រៀបរាប់ឡើងវិញទៀតទេ ។ ប៉ុន្តែ ខ្ញុំគ្រាន់តែសុំធ្វើសេចក្ដីបញ្ជាក់បន្ថែមបន្តិចបន្តួចអំពីពាក្យថា « ទោស » នេះជាពីរបែបទៅទៀត ៖

### ទី ១.- ការយកភាសាបារាំងជាយាន នាំឱ្យកាន់តែខ្សោយខាងភាសាបារាំងទៅវិញ.

កាលមុនសង្គ្រាមលោកលើកទី ១ នឹងទី ២ មនុស្សលោកយើងបែកជាពីរផ្នែកសំខាន់ គឺ :

– ១ ផ្នែក អ្នកមានបុណ្យមានអំណាចដើរជិះជាន់ប្លន់ទឹកដីគេ យកគេធ្វើជា “ ខ្ញុំ ” ខ្លួនឯងធ្វើជា “ ម្ចាស់ ” ។

– ១ ផ្នែកទៀត អ្នកទន់ខ្សោយ ត្រូវគេជិះជាន់សង្កត់សង្កិន ជាខ្ញុំកញ្ជះរបស់គេ ។ ក្នុងកំឡុងដ៏សែនយូរនៃការជិះជាន់របស់មហាអំណាចទាំងនោះ ប្រទេសទន់ខ្សោយ តែងតែកើតមានចិត្តក្ដៅក្រហាយ ឈឺចាប់ក្នុងអាត្មា ចេះភ្ញាក់សតិស្មារតី

ចំពោះអ្វីដែលជាតម្លៃរបស់ជាតិ អ្វីដែលជាសាច់ ស្ងួត ថ្លើម ប្រមាត់ របស់ជាតិ រង់ចាំតែឲកាសល្អនឹងចំរើបំរេះ ដណ្ដើមយកអ្វីៗ ទាំងឡាយនោះឲ្យបានមកវិញ ។

ឲកាសល្អក៏បានមកដល់ សង្គ្រាមលោកលើកទី ២ ក៏រលត់ទៅ ប្រទេសទន់ខ្សោយទាំងនោះក៏បានទទួលនូវពន្លឺឯករាជ្យសាជាថ្មី បន្ទាប់បន្តគ្នា ។ ដូចនេះគេតែងមានសេចក្ដីរីករាយសប្បាយចិត្តឥតឧបមា ព្រោះសង្ឃឹមថាអ្វីៗដែលខ្លួនប៉ងប្រាថ្នា ដែលខ្លួនសន្មតថាជាតម្លៃពិតប្រាកដរបស់ជាតិ មានវប្បធម៌-ភាសា-អក្សរជាដើមនោះ នឹងត្រូវបានមកខ្លួនវិញទាំងអស់ ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើបំណងទាំងនោះពុំបានសំរេចសមតាមសេចក្ដីប៉ងប្រាថ្នាទេ ខ្លួនក៏ពុំសប្បាយចិត្ត កើតក្ដៅក្រហាយ មួម៉ង ខូចចិត្ត ខូចស្មារតី រសេះរសោះខ្វីខ្វា រកតែចាប់កាន់ការអ្វីឲ្យពេញដៃពេញជើងស្ទើរពុំបាន... ។

នេះហើយ ជាកត្តាមួយយ៉ាងសំខាន់ណាស់ដែរ តាមយោបល់ខ្ញុំ ដែលធ្វើឲ្យសិស្សខ្មែរយើងរៀនកាន់តែខ្សោយទៅៗ ចំពោះភាសាបារាំង ព្រោះចិត្តគំនិតដែលមិនចង់ មិនស្រឡាញ់ មិនចូលចិត្ត ធ្វើឲ្យសិស្សភាគច្រើនក្នុងសម័យឯករាជ្យទៅជាធុញទ្រាន់ខ្វីខ្វា មិនយកចិត្តទុកដាក់ ចំពោះភាសាឥកដែលធ្លាប់ជិះជាន់ខ្លួន ហើយទីបំផុត ក៏ទៅជាខ្សោយទៅៗ ចំពោះភាសានោះ ទោះបីគ្រូខ្មែរក្ដី គ្រូជាតិបារាំងក្ដី ខំរកគិតគូកល វិធីដោះស្រាយយ៉ាងណា ឬ ទោះបីជាខំបង្កើនពេលម៉ោងយ៉ាងណាក៏ប្រៀបបាននឹងគេ " ចាក់ទឹកលើក្បាលទា " យ៉ាងនោះឯង ។

ដូចនេះការយកភាសាបារាំងជាយាននេះ ពុំមែនជាគុណទេ គឺប្រាកដជាទោសដ៏ជាក់ស្ដែងចំពោះអនាគតសិស្ស (ប្រហែលជាភាគច្រើន) គឺទោសដែលបណ្ដាលមកតែអំពីការភ្ញាក់រឭកនៃស្មារតីជាតិ ( réveil du sens national ) នេះ តែប៉ុណ្ណោះ ។

ប៉ុន្តែជាភ័ព្វល្អដែរ ចំពោះសិស្សខ្មែរយើងសព្វថ្ងៃ ដោយសារថា ពិតមែនតែច្បាប់តំរូវឲ្យយកភាសាបារាំងជាយានក្នុងការបង្រៀនក៏ដោយ ក៏សាស្ត្រាចារ្យខ្មែរយើង

គ្រប់មុខវិជ្ជាតែងតែនិយាយអធិប្បាយពន្យល់សិស្សយើង ដោយភាសាជាតិរបស់យើង ជាហេតុនាំឲ្យសិស្សទៅជាពូកែចង់ជាន់ជំនាន់ដើមទៅទៀតផង ចំពោះមុខវិជ្ជាគ្រប់ផ្នែក លើកលែងតែមុខវិជ្ជាខាងភាសាបារាំងចេញ ។

## ទី ២.– ការយកភាសាបារាំងជាយាន នាំឱ្យសិស្សបាត់បង់នូវបុគ្គលភាពរបស់ខ្លួន.

យើងជាគ្រូ យើងស្គាល់ ឬ ត្រូវតែស្គាល់នូវបញ្ហានេះ មុនអ្នកណាទាំងអស់ ។ ក្នុងការសិក្សាជាទូទៅ គេពុំមែនបង្រៀនសិស្សឲ្យចេះតែចំណេះវិជ្ជា ដែលគេចង់បង្រៀនតែម្យ៉ាងប៉ុណ្ណោះទេ ប៉ុន្តែគេនៅមានការចាំបាច់ នឹង អប់រំបន្ទុំចិត្តគំនិតស្មារតីរបស់សិស្សថែមទៀត ពោលដោយខ្លី គឺបណ្ដុះនូវ បុគ្គលភាព របស់សិស្សនេះឯង ។

តើគេមានមធ្យោបាយយ៉ាងណាខ្លះ ដើម្បីបណ្ដុះនូវបុគ្គលភាពរបស់សិស្ស ?

សូមឆ្លើយថា តាមគរុកោសល្យវិទ្យា (pédagogie) គេមានមធ្យោបាយច្រើនបែបច្រើនយ៉ាងណាស់ ដែលយើងពុំអាចរៀបរាប់ឲ្យល្អិតល្អន់អស់សេចក្ដីបានក្នុងទីនេះ ។ ប៉ុន្តែបើបង្រួមសេចក្ដីឲ្យខ្លីមក មធ្យោបាយចំពោះបញ្ហានេះ គឺមានតែពីរយ៉ាង :

ការចោទសួរ នឹងការឆ្លើយឆ្លង ។

ដូចនេះ ប្រសិនបើយោលទៅតាមគំនិតនេះ តើយើងអាចសំរេចបំណងខាងលើនេះបាន ឬទេ ?

តាមខ្ញុំយល់ ថាពុំអាចសំរេចបានទេ ព្រោះថា ៖

– ម្យ៉ាង ចំពោះគ្រូ កាលបើសួរបញ្ហាអ្វី ១ ទៅសិស្ស ហើយសិស្សស្ដាប់ចាប់សេចក្ដីមិនសូវបាន មិនសូវយល់ តើលទ្ធផលនឹងបានមកពីណា ?

–ម្យ៉ាងទៀត ចំពោះសិស្ស ឧបមាថាសិស្សអាចស្ដាប់បាទ់សេចក្ដី នៃពាក្យសួររបស់គ្រូបានទៅចុះ ( ដោយការគាត់ស្មានខ្លះៗ ) ប៉ុន្ដែ ដល់ពេលចង់ឆ្លើយ ឬចង់សាកសួរទៅគ្រូវិញ គ្មានពុំហ៊ានឆ្លើយ ពុំហ៊ានសួរ ពុំហ៊ានហើបមាត់ ព្រោះ " សូត្រក្បួនវេយ្យាករណ៍ " ( conjuguer ) បាពុំនពុំចេញ ម៉្លោះហើយគោនវៃតែនៅស្ងៀមទៅវិញជាធម្មតា – ដល់សម្រេចទៅ លទ្ធផលគឺគ្រូត្រូវតែនិយាយតែម្នាក់ឯងរហូត ហើយសិស្សជាអ្នកនៅចាំតែស្ដាប់តទៅទៀត

នេះហើយជាហេតុ ១ ទៀត នាំឲ្យសិស្សបាត់បង់នូវបុគ្គលភាពរបស់ខ្លួនបន្ដិចម្ដងៗរហូតទៅ ។

## សេចក្ដីសន្និដ្ឋាន.–

ដូចបានអធិប្បាយរៀបរាប់របមកហើយខាងលើនេះ យើងខ្មែរ គួរតែចាប់ចិត្ដប្រកាន់យកនូវគំនិតនៃខេមរនិយកម្មនេះ ឲ្យខ្ជាប់ខ្ជួនទាំងអស់គ្នា ។ ហើយបើយើងទាំងអស់គ្នា យើងមូលមាត់ស្រុះស្រួលគ្នាជាឯកច្ឆន្ទ ចំពោះបញ្ហានេះហើយ យើងត្រូវតែជួយពុះពារគាំទ្រ នូវឲ្យសត្គតាំងឡាយណាដែលជាការទើសទាស់ក្រឹកដំណើរនៃខេមរនិយកម្មនេះ មានការខ្វះខាតពាក្យពេចន៍ ខ្វះខាតសៀវភៅ ខ្វះខាតបុគ្គលិកជាដើម ដោយជួយបង្កើតពាក្យ ជួយសរសេរសៀវភៅ ជួយបកប្រែ ជួយជាមតិ គំនិត យោបល់យ៉ាងណាឲ្យខាងតែបានសំរេចនូវគោលបំណងដ៏សំខាន់ ១ នេះ ដើម្បីជាប្រយោជន៍ជាតិយើងផង ជាកិត្តិយសដល់ជាតិយើងផង ដើម្បីបណ្ដុះស្មារតីជាតិនិយមពិតប្រាកដផង ហើយជាពិសេស ដើម្បីគាំពារកេរ្តិ៍ស្មារតី នៃបុព្វបុរសយើង មានព្រះមហាវីរក្សត្រដ៏ចំណានៗ ដែលក្នុងចំណោមនោះ ព្រះបាទសម្ដេចព្រះអង្គឌួង នឹងព្រះនរោត្តម ដែលព្រះអង្គខិតខំបណ្ដុះបណ្ដាល

លើកតំកើងវប្បធម៌ជាតិយើងខ្លាំងណាស់ មានភាសា-អក្សរនេះជាដើម ។ សូមឲ្យវិញ្ញាណក្ខន្ធដ៏ថ្លាត្រចង់របស់ព្រះអង្គទាំងនោះ បានទទួលនូវការសប្បាយរីករាយដោយសារយើងផង ដោយឃើញថា យើងបានខិតខំពុះពារគោរពតាមតម្រាប់តម្រាយដ៏ល្អប្រពៃរបស់ព្រះអង្គពុំមានខ្ចោះ ។

ជាពិសេសណាស់ទៅទៀត យើងត្រូវតែតបស្នងព្រះមហាករុណាទិគុណរកទីបំផុតគ្មាន នៃសម្ដេចឪយើងផង គឺព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុវរ្ម័ន ព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិខ្មែរ ព្រះប្រមុខរដ្ឋខ្មែរ ព្រះបិតានៃវប្បធម៌ខ្មែរ ដែលព្រះអង្គបានខំពុះពារមិនគិតដល់ព្រះជន្មាយុ ដើម្បីទាមទារយកឯករាជ្យពិតប្រា-កដបានមកជូនជាតិយើងវិញនោះ ដោយយើងខំជួយជំរុញចលនាខេមរនីយកម្មក្នុងការសិក្សានេះ ជាពិសេសនឹងក្នុងការទាក់ទងរវាងខ្មែរគ្នាឯងជាទូទៅ ឲ្យខាងតែបានសម្រេចជាស្ថាពរ ។

ជយោភាសាខ្មែរ !

---

## មិត្តទាំងឡាយ !

យោបល់ល្អក្ដី វិជ្ជាថ្មីក្ដី ដែលមិត្តយកទៅពន្យល់ បង្រៀនក្នុងថ្នាក់មានប្រយោជន៍ធំហើយ តែបើមិត្តសរសេរ ហើយផ្ញើទៅផ្សាយក្នុងទស្សនាវដ្ដីយើងថែមទៀតនោះ នឹងមានប្រយោជន៍កាន់តែធំក្រៃលែងណាស់ទៅទៀត ។

# ខេមរនីយកម្ម

ឡោក ធូត
អនុវិទ្យាល័យដម្លូវ័ន — កណ្ដាល

ទស្សនាវដ្ដីសាស្ត្រាចារ្យសូមថ្លែងនូវសេចក្ដីសរសើរចំពោះមិត្ត ឡោក ធូត ដែលបានស្រាវជ្រាវរកភស្ដុតាងផ្សេងៗមកបញ្ជាក់ចំពោះបញ្ហាជាច្រើន ដូចជាបញ្ហា អក្ខសាស្ត្ររបស់ខ្មែរ-ធ្វើតាម — ការប្រទាញមិនទាន់ចប់...ជាដើម ។ ប៉ុន្ដែ ដោយបញ្ហាទាំងនេះជាប់ទាក់ទងមិនសូវខ្លាំងទៅនឹងបញ្ហាខេមរនីយកម្ម យើងសូមមិត្តមេត្តាឲ្យយើងចុះតែអត្ថបទមួយ ដែលមានចំណងជើងថា " ខេមរនីយកម្ម " តែប៉ុនោះ ។

ក្រោយពីបង្ហាញថា ក្មេងខ្សោយបារាំង មកពី " ទន្ទេញគតយល់និយម " និង មកពីការហាត់ប្រាណនៅពេលដិតថ្ងៃត្រង់មក មិត្ត ឡោក ធូត សរសេរថា :

*យើង បានឃើញរួចមកហើយនូវ " មារ " ដែលមកជ្រៀតជ្រែកលើវត្ថុធាតុសំរាប់ទ្រទ្រង់ចលនានៃការលូតលាស់របស់យុវជនខ្មែរ ។ ដូចខ្ញុំបានជំរាបអស់មិត្តថា អ្នកផ្ទៀតឲ្យកាសនិយមមុខជាហ៊ានអះអាងថា គ្មាន "មារ" ឯណាមកជ្រែកទេ ព្រោះបញ្ហានេះជាការងាយដោះស្រាយបំផុត គឺគ្រាន់តែឲ្យសិស្សចាប់រៀនសូត្រភាសាបារាំងពីថ្នាក់ទី ១១ មក, ដរាបណាសិស្សពូកែបារាំង សិស្សអាចចាប់យកបាន ទទួលបាននូវពុទ្ធិគ្រប់បែបយ៉ាង ៗ ចំពោះរូបខ្ញុំវិញ ដោយយោលទៅតាមការអាប់អួ ថោកទាប ឧបសគ្គ... គ្រប់អន្ទើដែលយើងបានឃើញរួចមកហើយ យើងមិនត្រូវឲ្យយុវជនរៀនភាសាបារាំងចាប់តាំងពីថ្នាក់ទី ១១ មកវិញទេ ពុំនោះសោតយុវជនត្រូវដើរថយក្រោយចូលទៅ ក្នុងសម័យអាប់អួដែលផ្ដល់កំណើតនៃពាក្យទំបារាំង - ស្កបារាំង... ។ យើងត្រូវធ្វើយ៉ាងណាឲ្យយុវជនចាប់ចិត្ត*

ទៅលើសេចក្ដីរុងរឿងចំរើន មានសម័យដែលប្រាសាទខ្មែរដុសផុះចេញដូចផ្សិតជាដើម ។ តើនៅសម័យអង្គរ ខ្មែររុងរឿងដោយសារការនិយមប្រើភាសានៃពួក "ក្អែកប្រាក់" ឬ ? តើខ្មែរជំនាន់នោះបេះផ្កាយ ទទួលពុទ្ធិបានឬទេ ? ។ ក្រោមការដឹកនាំដ៏ភ្លឺស្វាងនៃសម្ដេចឪ នារោត្តមជាបានប្រាសចាកពីនឹមបារាំង ហើយប្រជាជាតិខ្មែរចំដុសលាងកំអែលដែលអាណានិគមទុកឲ្យ ។ អក្សរសាស្ត្រខ្មែរដែលបានលូតលាស់ មានសន្ទុះល្អតាំងពីបានឯករាជ្យមកត្រូវការរំដោះគ្រោះ ដូចទឹកលាងក្អែលឲ្យអស់ពីខ្លួន ឡើងកាន់ឋានៈខ្ពង់ខ្ពស់មានមុខមាត់ដូចគេឯង ។ ម្យ៉ាងទៀត ប្រជាជាតិទាំងឡាយក្នុងសាកលលោករមែងតែងសិក្សាភាសានានា ក្នុងឋានៈជាភាសាបរទេស ។ ដរាបណាយើងធ្វើដូច្នេះ យុវជនខ្មែរមុខជាពូកែភាសាបរទេសដែលគេតំរូវឲ្យរៀន មានភាសាបារាំងជាអាទិ៍ អាចទទួលពុទ្ធិគ្រប់បែបគ្រប់យ៉ាងបានដោយស្រួល ដោយមិនចាំបាច់សូត្រទន្ទេញដូច "គម្ពីរវេទ" ហើយមានគំនិតស្មារតីក្នុងផ្លូវ "អ្នកជាតិនិយម" ព្រោះខ្មែរ "អ្នកជាតិនិយម" ត្រូវនិយមរបស់ជាតិខ្មែរ :

អក្សរខ្មែរមាន – ត្រូវនិយមអក្សរខ្មែរ

ភាសាខ្មែរមាន – ត្រូវនិយមភាសាខ្មែរ ។

ហេតុនេះហើយ បញ្ហាខេមរនីយកម្មជាបញ្ហាចាំបាច់បំផុត ។

---

តើយើងត្រូវធ្វើខេមរនីយកម្ម មួយថ្នាក់ម្ដង មួយថ្នាក់ម្ដង ឬ យ៉ាងណា ?

តាមធម្មតា ក្មេងកើតកមរមាស់នៅក្បាល នៅដៃ នៅជើង ។ល។ គ្រូពេទ្យមិនដែលព្យាបាលក្បាលម្ដង ដៃម្ដង ជើងម្ដង... នោះទេ គឺត្រូវមើលព្យាបាលទាំងក្បាល ទាំងដៃទាំងជើង... ពុំនោះសោត កមរមាស់មិនជាសោះជាដាច់ខាត ។ បញ្ហាខេមរនីយកម្មនេះ មិនខុសគ្នានឹងបញ្ហាព្យាបាលកមរមាស់ខាងលើនេះទេ ។ ប្រសិនបើយើងធ្វើការសាក

ពិសោធន៍នៅថ្នាក់ទី ៦ រួចប្រឹងកែច្នៃ ហើយកែច្នៃទៀតរាប់ឆ្នាំ លុះឃើញថាល្អទើបហ៊ានបន្តទៅថ្នាក់ទី ៤ ទៀត — នៅថ្នាក់ទី ៤ នេះទៀត ការសាកពិសោធន៍ត្រូវប្រើពេលរាប់ឆ្នាំដូចមុន — ខេមរនីយកម្មមុខជាត្រូវប្រើពេលរាប់សតវត្សទើបបានសំរេចផល ! ស្នៀតនេះពុំគាប់ប្រសើរទេ ព្រោះយុវជនដែលធ្លាប់រៀនសូត្រគ្រប់មុខវិជ្ជាជាខ្មែរនៅថ្នាក់ទី ៦ លុះបានឡើងទៅថ្នាក់ទី ៤ ដែលគេតំរូវឲ្យរៀនជាភាសាបារាំងទៅវិញ នឹងធ្លាក់ខ្លួនចុះទៅក្នុងជ្រោះជ្រៅងងឹតសូន្យសុង ប្រកបដោយគ្រោះថ្នាក់ធ្ងន់ជាងសព្វថ្ងៃនេះទៅទៀត ។

ឧទាហរណ៍ : សព្វថ្ងៃនៅថ្នាក់ទី ៦ ភូមិវិទ្យា ប្រវត្តិវិទ្យា អាចចាត់ទុកជាឧសថកែរោគ ដែលធ្វើឲ្យយុវជនស្រួលគិត ស្រួលនិយាយ ស្រួលសរសេរ... ព្រោះការបង្រៀនត្រូវប្រព្រឹត្តជាភាសាខ្មែរ ។ លុះដល់ថ្នាក់ទី ៤ ភូមិវិទ្យា ប្រវត្តិវិទ្យាត្រូវចូលសញ្ជាតិជាបារាំង ប្រែក្លាយជាថ្នាំពុល ធ្វើឲ្យយុវជនមានគំនិតវិលវល់ ថាពាក្យបារាំងមិនចង់ចេញ និយាយមមើមមាយ សរសេរខុសជាសទឹកជាសដី –ល–... ។

## មិត្តទាំងឡាយ !

តែងមេរៀនជាភាសាខ្មែរ ហើយផ្ញើទៅចុះក្នុងទស្សនាវដ្ដីសាស្ត្រាចារ្យរបស់យើងរាល់គ្នា ជាអំពើប្រពៃណាស់ — ប្រពៃព្រោះបានផ្សាយការចេះដឹងដល់អ្នកអាន — ប្រពៃបំផុតទៅទៀត ព្រោះបានបង្ហាញថា អក្សរនិងភាសាខ្មែរអាចប្រើជាយានក្នុងការសិក្សា ។




## តើស្អប់ ឬស្រឡាញ់មកពីមុខវិជ្ជា ឬ ?

សុក ឡាមីន

វិទ្យាល័យជ័យវរ្ម័នទី ៧

អត្ថបទខាងក្រោមនេះ ជាចម្លើយចំពោះប្រធានដែលយើងបានចោទក្នុងទស្សនាវដ្ដីយើងលេខមុន ។ យើងសូមឲ្យមិត្តអ្នកអាន ពិចារណាទាញយោបល់អំពីអត្ថបទនេះ ដោយខ្លួនឯងចុះ ។

បើ តាមយោបល់ដ៏ស្តួចស្តើងរបស់ខ្ញុំ ខ្ញុំយល់ឃើញថា ការដែលសិស្សស្រឡាញ់តែគ្រូបង្រៀនមុខវិជ្ជានេះ ហើយស្អប់គ្រូបង្រៀនមុខវិជ្ជាបែបនោះ គឺ ដោយមានបុព្វហេតុពីរយ៉ាងដូចតទៅ :

១– មកពីកំហុសរបស់គ្រូយើង

២– មកពីកំហុសរបស់សិស្ស

១– កំហុសរបស់គ្រូ – ហេតុដែលបណ្ដាលឲ្យសិស្សស្អប់ លោកគ្រូបង្រៀនមុខវិជ្ជាអ្វីម្យ៉ាង គឺដោយហេតុថា លោកគ្រូនោះបង្រៀនមុខវិជ្ជាពុំបានច្បាស់លាស់ ពោលគឺ

ពន្យល់សិស្សស្ដាប់មិនសូវបាន  មានលឿនពេក ឬ យឺតពេក ឬ ក៏ពុំសូវយកចិត្តទុកដាក់
បង្រៀនមុខវិជ្ជានោះឲ្យជិតដល់តែម្ដង ៗ កាលបើសិស្សស្ដាប់សេចក្ដីពន្យល់របស់លោក
គ្រូមិនបានហើយ សិស្សក៏តាំងមានការធុញថប់ ស្អប់មុខវិជ្ជានោះ រួចក៏តាំងខ្ជិលរៀនបន្តិច
ម្ដង ៗ ទាល់តែខ្វាយរហូតដល់លែងចង់ចូលថ្នាក់រៀនមុខវិជ្ជានោះថែមទៀតផង ៗ សិស្ស
នឹកថា បើសិនជាខ្លួនចូលរៀនមុខវិជ្ជានេះទៀត ក៏នៅតែស្ដាប់មិនបានដដែល (ជាពិសេស
គឺមុខវិជ្ជាដែលជាភាសាបរទេស ដូច គីមី អង់គ្លេសជាដើម ) ដូច្នេះ ហើយបានជាសិស្ស
មានការរសាយចិត្តគំនិតពីមុខវិជ្ជា ដែលខ្លួនស្ដាប់ពុំសូវយល់ ឬ ក៏ពុំយល់ទាល់តែសោះ ៗ
មានគ្រូយើងខ្លះ ចេះវិធីបង្រៀនសិស្សឲ្យឆាប់យល់ ឆាប់ធ្វើតាមបាន តែពាក្យសំដីគំរោះ
គំរើយខ្លាំង ឬ ក៏មានបុគ្គលិកពុំថ្លៃថ្នូរ មានប្រព្រឹត្តអ្វីៗ គ្គាំគ្គងនាំឲ្យសិស្សព្រាប់ថ្នាក់បាន មាន
ការស្រឡាញ់សិស្សពុំស្មើគ្នា ដូចជាចូលចិត្តតែសិស្សស្រីៗ ឲ្យពិន្ទុច្រើន ឯសិស្សប្រុសៗ
ឲ្យពិន្ទុតិច ៗ កំហុសគ្រូយើងបែបនេះ នាំឲ្យសិស្សស្អប់ជាពិតប្រាកដ ៗ

ខ្ញុំបាទនិយាយនេះ គឺពុំមែនចង់រិះគន់ ឬ ដាក់កំហុសអ្វីដល់គ្រូបង្រៀនយើងទេ គឺ
និយាយដោយបានស្ដាប់ឮច្បាស់ពីពាក្យសំដីរបស់សិស្សភាគខ្លះ ដែលតែងតែទំលាក់ទោស
មកលើបុគ្គលិកសិក្សាយើង ដោយសំអាងថា លោកគ្រូនេះបង្រៀនញាប់ពេក រង្វើលពេក
ស្ដាប់មិនសូវបាន និយាយមិនច្បាស់ បើត្រូវការសួរគាត់ គាត់ស្រែកគំហកឲ្យអង្គុយ ឬ
បង្អាប់ឲ្យខ្មាសគេ ៗ

មួយវិញទៀត ហេតុដែលបណ្ដាលឲ្យគ្រូយើងទទួលកំហុសបែបនេះ គឺធំបំផុតនៅ
ត្រង់ដែលគ្រូពុំសូវប៉ិនប្រសប់បង្រៀនខាងមុខវិជ្ជាណាមួយ ហើយគេតម្រូវឲ្យខ្លួនបង្រៀន
ដោយខានមិនបាន ព្រោះថា នៅអនុវិទ្យាល័យក្ដី នៅវិទ្យាល័យក្ដី គ្រូភាគតិចណាស់ដែល
ត្រូវបង្រៀនវិជ្ជាតែមួយមុខ តែភាគច្រើន គឺបង្រៀនច្រើនមុខ ៗ ឧទាហរណ៍ ដូចជាគ្រូ
ម្នាក់បង្រៀនខ្មែរផង បារាំងផង គីមីផង វិទ្យាសាស្ត្រធម្មជាតិផង ជាពិសេស គឺច្រើនតែ

គ្រូបង្រៀនបំពេញវិជ្ជា ឯសាស្ត្រាចារ្យគេច្រើនឲ្យបង្រៀនតែមួយមុខ ឬ យ៉ាងច្រើនត្រឹមពីរមុខ ៗ យើងក៏សឹងជ្រាបដែរហើយថា គ្រូយើងតិចណាស់ដែលពូកែមុខវិជ្ជាគ្រប់ផ្នែក ភាគច្រើន គឺពូកែមុខនេះ អន់មុខនោះ ឬក៏មិនច្បាស់សឹងតែទាំងអស់ថែមទៀតផង ហើយការដែលបង្រៀនច្រើនមុខដូច្នេះ នាំឲ្យមានការពិបាកប្រុងប្រៀបរៀបចំជាខ្លាំង ពោលគឺប្រឹងរៀបចំមុខវិជ្ជានេះផង មុខវិជ្ជានោះផង បើពូកែតែទាំងគ្រប់ទៅក៏អាចបង្រៀនទៅបានស្រួល ៗ ចុះបើអន់វិជ្ជាណាមួយ ហើយគេតម្រូវឲ្យបង្រៀនដោយខានពុំបាន ដូច្នេះឃើញថាវិជ្ជាដែលអន់នោះបង្រៀនទៅមិនបានលទ្ធផលល្អទេ ព្រោះមិនសូវចេះ ហើយសុំតែរួចខ្លួនប៉ុណ្ណោះ ទោះបីសិស្សយល់ ឬ មិនយល់ក្តី ៗ

ដូច្នេះ ការដែលនាំឲ្យសិស្សស្អប់គ្រូ គឺមានមូលហេតុ និង អត្ថទោស ដូចតទៅ :

ក– ស្អប់ដោយបង្រៀនមិនកើត

ខ– ស្អប់ដោយគ្រូមានពាក្យសំដីពុំពីរោះ

គ– ស្អប់ដោយមានកិរិយាមារយាទពុំថ្លៃថ្នូរ

ឃ– ស្អប់ដោយមានការអយុត្តិធម៌ក្នុងការឲ្យពិន្ទុ ៗ

ឯគ្រូបង្រៀនមុខវិជ្ជាណាមួយ ដែលសិស្សស្រឡាញ់វិញ គឺដោយហេតុ គ្រូនោះចេះបង្រៀនច្បាស់លាស់ ចេះប្រើគលល្បិចសព្វបែបយ៉ាង ដែលធ្វើឲ្យសិស្សងាយស្តាប់ ងាយយល់ ងាយត្រងត្រាប់ ពុំនោះសោត ចេះនិយាយកំប្លែងខ្លះ ៗ ដែលទាក់ទងក្នុងការអប់រំសិស្ស ធ្វើឲ្យសិស្សសប្បាយរីករាយបានគ្រប់ពេល ៗ ម្យ៉ាងទៀត សិស្សដែលស្រឡាញ់គ្រូក៏ដោយខ្លួនសង្កេតឃើញកិរិយាមារយាទគ្រូថ្លៃថ្នូរ មិនលេងសើចខុសរបៀប មិនមានការប្រកាន់បក្ខពួកហួសហេតុ មានចិត្តទន់ភ្លន់ និយាយអ្វីច្រើនសមហេតុសមផល ហើយបើកឲ្យសិស្សសួរបានគ្រប់ពេលទាំងអស់ កាលបើខ្លួនស្តាប់អ្វីៗ ពុំយល់ ៗ ពិសេសជាងនេះទៅទៀត គ្រូដែលធ្វើឲ្យសិស្សស្រឡាញ់បាន គឺគ្រូដែលចេះទាក់ទាញអារម្មណ៍

សិស្សទៅលើមុខវិជ្ជាដែលខ្លួនបង្ហាត់បង្រៀន ហើយធ្វើឲ្យសិស្សពេញចិត្តចង់តែមករៀន គ្រប់ពេលវេលា ៗ តាមខ្ញុំបាទយល់ ទាល់តែមានលក្ខណៈបែបនេះ ទើបសិស្សអាចស្រឡាញ់បាន ហើយទោះបីជាមានសិស្សខ្លះព្រហើនកោងកាច ក៏វាមិនហ៊ានមើលងាយ ឬ ស្អប់ខ្ពើមយើងខ្លាំងដែរ ៗ

**២– កំហុសរបស់សិស្ស–** តាមធម្មតា កំហុសគឺពិតជាធ្លាក់ទៅលើសិស្សមួយភាគធំ ពោលគឺសិស្សខ្លះខ្សោយស្រាប់នូវមុខវិជ្ជាណាមួយ ហើយដល់ពេលរៀនមុខវិជ្ជានោះ មិនសូវយកចិត្តទុកដាក់ ទោះបីគ្រូខំបង្រៀនយ៉ាងណាក៏ដោយ ហើយដល់ពេលគ្រូតឹងតែងឲ្យពិន្ទុតិចតួចសមទៅតាមភាពខ្ជិលច្រអូសរបស់ខ្លួន ក៏តាំងគុំស្អប់គ្រូនោះភ្លាម ៗ សិស្សខ្លះមានការធុញថប់ មិនចង់រៀនជាមួយនឹងគ្រូណាដែលមានការតឹងរឹងខ្លាំង មិនចង់រៀនជាមួយនឹងគ្រូណាដែលលេងសើចច្រើនហួសហេតុ ជាពិសេស គឺគ្រូដែលមិនចេះធ្វើឲ្យត្រូវចិត្តខ្លួន ខ្លួនក៏តាំងស្អប់ព្រមទាំងដាក់ងារឲ្យគ្រូឈ្មោះបែបនេះ ឬ ឈ្មោះបែបនោះ តាមតែខ្លួននឹកឃើញ ជួនកាលរហូតដល់ទៅនិយាយដៀមដាមបញ្ឆិតបញ្ឆៀង ឲ្យគ្រូឮច្បាស់ៗទៀតផង ៗ គ្រូយើងខ្លះខំបង្រៀនមុខវិជ្ជាបានល្អឥតខ្ចោះ តែសិស្សមិនព្រមយកចិត្តទុកដាក់ស្ដាប់សេចក្ដីពន្យល់ គិតតែសើចលេងសប្បាយក្នុងថ្នាក់ ដល់គ្រូស្ដីបន្ទោសបន្តិចបន្តួច ឬ ឲ្យដំបូន្មាន ដើម្បីឲ្យកែខ្លួន ក៏ត្រឡប់ជាស្អប់គ្រូ ថាគ្រូមិនចូលចិត្តខ្លួន ហើយបង្អាប់ខ្លួនច្រើនជាងគេ ៗ តែជួនកាលសិស្សស្អប់មុខវិជ្ជា ដែលខ្លួនរៀនមិនលូតលាស់ ហើយបណ្ដាលឲ្យទៅជាស្អប់គ្រូបង្រៀនមុខវិជ្ជានោះទៅវិញ ៗ

បើសិស្សបែរជាស្រឡាញ់គ្រូបង្រៀនមុខវិជ្ជាណាមួយ គឺបានសេចក្ដីថា សិស្សពេញចិត្តនឹងគ្រូបង្រៀនល្អ មិនលឿនពេក ឬ យឺតពេក អាចឲ្យខ្លួនស្ដាប់យល់បានគ្រប់ពេល ៗ ហើយគ្រូនេះទៀត ក៏មានយុត្តិធម៌ល្អ មិនស្អប់ ឬ កាន់ជើងសិស្សម្នាក់ៗ (ប្រុស ឬ ស្រី),

ជាពិសេស គឺគ្រូណាដែលគ្មានការតឹងរ៉ឹងខ្លាំង ឬ បន្ធូរបន្ថយហួសពេក ។ ឬក៏ថា គ្រូដែលធ្វើឲ្យសិស្សស្រឡាញ់បាន គឺមកពីលោកចេះប្រើភាពផ្អែមល្ហែម ចេះលើកទឹកចិត្តសិស្សគ្រប់ពេល ទោះឆ្លើយខុសក្ដី ត្រូវក្ដី ហើយជៀសវាងបាននូវការបង្អាប់ផ្សេង ៗ ។ តែទោះបីជាល្អឥតខ្ចោះបែបនេះ ក៏នៅតែមានសិស្សខ្លះអាចស្អប់បានដែរ ព្រោះមនុស្សមិនអាចធ្វើឲ្យត្រូវចិត្តមនុស្សសព្វគ្រប់ទេ ។

យោបល់រួម– ដូច្នេះគ្រូដែលបង្រៀនមុខវិជ្ជានេះ ឬមុខវិជ្ជានោះ ធ្វើឲ្យសិស្សស្អប់ ឬស្រឡាញ់ ក៏មកតែពីចរិយានិងការបង្ហាត់បង្រៀនល្អ មិនល្អនោះជាពិតប្រាកដ ។ នៅវិទ្យាល័យក្ដី ឬ អនុវិទ្យាល័យក្ដី សិស្សភាគច្រើន គឺសុទ្ធតែឋិតក្នុងយោព្វនវ័យអាចពិចារណារកហេតុផលបានសព្វគ្រប់ ដូចមនុស្សចាស់ទុំដែរ ។

ដូច្នេះ គ្រូមិនអាចនិយាយកុហក ឬ ពន្យល់អ្វី ៗ ដែលប្រាសចាកហេតុផលហើយឲ្យសិស្សអនុមតិតាមដោយងាយ ៗ នោះបានឡើយ ។ ទាល់តែនិយាយពន្យល់អ្វីសមហេតុផលល្អ ឬ បង្រៀនមុខវិជ្ជាត្រូវតាមក្បួនខ្នាត និងមានមធ្យោបាយប្រសើរផ្សេង ៗ ដែលអាចនាំឲ្យសិស្សឆាប់យល់ ឆាប់ចាំ ឆាប់ប្រតិបត្តិតាមបាននោះ ទើបសិស្សស្រឡាញ់ ៗ ផ្ទុយទៅវិញ បើសិនជាកុហកសិស្ស ឬ និយាយអ្វីដែលពុំសូវសមហេតុផល និងបង្រៀនមុខវិជ្ជាមិនយកចិត្តទុកដាក់ឲ្យដិតដល់ សិស្សមុខជាស្អប់ហើយមើលងាយជាមិនខាន ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ស្រេចតែនៅលើការវិនិច្ឆ័យរបស់សិស្សទៅវិញទេតើ ? ព្រោះថា គ្រូខ្លះបង្រៀនមិនល្អ មានសិស្សខ្លះបែរជាថាល្អ ព្រោះខ្លួនស្រឡាញ់ពេញចិត្ត ខ្លះទៀតបង្រៀនល្អ តែសិស្សមិនពេញចិត្ត បែរជាថាមិនល្អ ហើយស្អប់ទៅវិញ ។



# វិទ្យាសាស្ត្រ និង [illegible]

## ឥទ្ធិពលនៃវប្បធម៌

ព្រុំ សំអាត

មហាវិទ្យាល័យ សិល្បៈ និងមុទ្ទរបរ

ពួកអាណានិគមនិយម កាលណាគេបានកាន់អំណាចត្រួតត្រាលើស្រុកណាមួយហើយ គេត្រូវការរស់នៅដោយសន្តិភាពក្នុងស្រុកនោះ ដើម្បីមានពេលស្រូបផ្ចិតយកធនធាន របស់ខ្លួនបានបំពេញជាអតិបរិមា ។ ដើម្បីគោលបំណងនេះ គេត្រូវធ្វើឲ្យអ្នកស្រុកដែលគេត្រួត ស្រឡាញ់គេ យ៉ាងស្មោះត្រង់ គឺឲ្យភ្លេចគិតតាមការឯករាជ្យជាតិ ។ វិធីបំបែកបំបាក់លើកមួយដាក់មួយ ធ្វើស្រឡាញ់មួយ ស្អប់មួយ ធ្វើហាក់ដូចជាសប្បុរសរវាងអ្នកនេះ តែបង្ក្រាបអ្នកនោះជាគំរូ ក្តិចពន្លកកម្លាំងចំរើន ពង្រីកកម្លាំងពុករលួយ ជីវភាពវេទនាវេវស នេះជាវិធីទូទៅមួយផ្នែកនៃពួកអាណានិគមនិយម ។

ទោះបីវិធីទាំងប៉ុន្មានខាងលើនោះ អាចហុចផលបានយ៉ាងណាក៏ដោយ ក៏ពួកអាណានិគមនិយមនៅតែយល់ថា វិធីនេះមិនទាន់ប្រពៃមែនទែនទេ គេត្រូវប្រើវិធីម្យ៉ាងទៀតទើបបង្រួបប្រទេសខ្ញុំគេ បានស្រួល បានយូរអង្វែង គឺវិធីប្រើឥទ្ធិពលតាមវប្បធម៌ មានភាសានេះជាដើម ។

បារាំងអាណានិគមនិយមទៅគ្រប់គ្រងប្រទេសណាមួយ គេតែងបង្កើតសាលាបារាំងឲ្យប្រទេសនោះរៀន ហើយនរណាចេះបារាំង គេឲ្យបុណ្យស័ក្ដិធ្វើធំ បានទទួលផលប្រយោជន៍ច្រើន ។ ជប៉ុនអាណានិគមនិយមនៅប្រទេសខ្មែរយើងជាដើម ក៏ដូចនោះដែរ មិនទាន់កាន់អំណាចទាំងស្រុងផង គេចាប់បង្រៀនភាសាគេភ្លាម ហើយគេឲ្យតម្លៃទៅលើនរណាចេះភាសាគេ មានឲ្យធ្វើជាអ្នកបកប្រែប្រកបនូវប្រាក់ខែច្រើនជាដើម ។ អាណានិគម អង់គ្លេស ហូល្លង់ ។ល។ ក៏ដូចនោះទៀត ដូចជានៅប្រទេសឥណ្ឌូណេស៊ី ជាអាទិ ។ ផ្ទុយមកវិញ ពួកអាណានិគមនិយមទាំងនោះ គេបន្តុះបង្អាប់ បន្ថោក ហើយទាត់ចោលតែម្ដង ដោយសេចក្ដីគួរសមផងទៀត នូវភាសាជាតិរបស់ប្រទេសដែលគេគ្រប់គ្រង ។

គេប្រើវិធីបញ្ចូលភាសាដើម្បីផ្សាយឥទ្ធិពលរបស់គេ ពីព្រោះភាសាអាចនាំវប្បធម៌គេចូលដល់បេះដូងថ្លើមប្រមាត់មនុស្សដែលគេគ្រប់គ្រង ហើយដែលមិនភ្ញាក់រលឹក បានដោយងាយ ៗ តាមភាសាគេ គេអាចបង្ហាញដល់ស្រុកខ្ញុំគេ នូវសម្រស់ភាសាគេ នូវជីវភាពខ្ពង់ខ្ពស់នៃវណ្ណៈមូលធនកាន់អំណាចរបស់គេឲ្យអ្នកខ្ញុំគេកោតសរសើរ ស្ងើចរហូតដល់ខ្ចប់នូវទស្សនៈនៃអ្នកនិពន្ធពុករលួយ ប្រតិកិរិយា ដើម្បីឲ្យអ្នកដែលគេគ្រប់គ្រងវង្វេងស្រើបស្រាល ធ្វើតាម ក្បួនសេចក្ដីស្នេហាសេរីភាព និងសិទ្ធិមនុស្ស ។ យុវជនក្រោមអាណានិគមនិយមដែលរៀនពីអត្ថបទ « លើឡាក់ » នរណាក៏និកស្ងើចសរសើរតាមគ្រូបង្រៀនដែរ ។ គេស្រឡាញ់កំណាព្យនោះ ហើយពិសេសទៅទៀត គេស្រឡាញ់ណាស់ ពីព្រោះជាកំណាព្យស្នេហាបកស្រាយរាប់រៀបពីសេចក្ដីទុក្ខទឹងអស់សង្ឃឹម ឬ មានសង្ឃឹមក្នុងស្នេហា រាសែនត្រូវចំណុចចិត្តគេដែលនៅក្នុងភាពយុវវ័យខ្ចីសេចក្ដី ។ អូ ពីរោះណាស់ នាំគ្នាទន្ទេញ !

« លើស៊ីដ » ក៏ដូចនោះដែរ សំដែងឲ្យឃើញពីការនិយមអាត្មា មានឃ្លាល្បះល្អពាក្យមួយម៉ាត់ៗរាប់ចំន័យតែម្ដង ។ លោកស្វាតូប្រ៊ីយ៉ង់ ក៏សរសេរល្អណាស់ លោកចេះនិយាយអណ្ដែតអណ្ដូងក្នុងសិល្បៈដើម្បីសិល្បៈ ។ លោកមុស្សេ ក៏ជាទីអស្ចារ្យមួយទៀតក្នុងទស្សនៈមូលធន ។ លោកវីញី ក៏វិសេសណាស់ទៅទៀត ខាងផ្សាយមតិកុំគស៊ី

នឹងសេចក្ដីលំបាកផ្សេងៗ ពីព្រោះធ្វើម៉េចកើតមកពយ៉ាងដូចនេះទៅហើយ ខំទ្រាំឲ្យផុតមួយជីវិតទៅចុះ ។ ភាសាបារាំងគេមានពាក្យច្រើនណាស់សំរាប់ « នុយអង្ស » សំរាប់ន័យប្លែកៗ ។ មួយថ្ងៃៗ សិស្សក្រោមអាណានិគមនិយម រៀនតែភាសាបរទេសនោះ ឃើញតែតម្លៃភាសារបស់គេ ។ ពេលរៀនភាសាជាតិរបស់ខ្លួនវិញ អ្នកចាត់ការដែលជាជាតិបារាំងអាណានិគមនិយម គេមិនរវល់គិតគូរ នរណាចង់រៀនរៀនទៅ គេបង្កើតឲ្យមានតែមុខវិជ្ជានោះ ទុកគ្រាន់នឹងធ្វើជាជីវភាសា ឬគ្រាន់តែដើម្បីកុំឲ្យមានពាក្យនិន្ទាថា គេមិនឲ្យរៀនភាសាជាតិប៉ុណ្ណោះ ។ កាលណាសិស្សជាប់ស្នេហ៍វប្បធម៌របស់គេ ហើយបង្អាប់ភាសាជាតិខ្លួនវិញ មិនយកចិត្តទុកដាក់នឹងរៀនសោះ ដូនណាបារាំងនោះគេមកធ្វើជានិយាយដាស់តឿនថា អ្នកឯងគួរខំរៀនភាសាជាតិអ្នកឯងទៅ ។ ស្ដាប់ឮសំដីនេះភ្លាម យើងគិតទៅហាក់ដូចជាគេល្អណាស់ សិស្សគ្រាន់តែជឿថាគេល្អ ហើយប្រសិនបើខ្លួនមិនរៀនភាសាខ្លួន ក៏ពីព្រោះតែខ្លួនមិនស្រឡាញ់ មិនឃើញមានអត្ថប្រយោជន៍នៃភាសាខ្លួននោះ មិនមែនមកពីគេមិនណែនាំឲ្យរៀនឡើយ ផ្ទុយទៅវិញ ឃើញទេគេដាស់តឿនឲ្យរៀនផង ។ " ខំរៀនភាសាជាតិខ្លួនទៅ ! " ខ្លាចអ្វីនឹងថាពាក្យមួយម៉ាត់នេះ បើសិស្សជ្រប់នឹងវប្បធម៌គេទៅហើយ ។


**បណ្ណាគារ វិជ្ជាទិព្វ**

លេខ 524 វិថីកម្ពុជាក្រោម ភ្នំពេញ

មានសេចក្ដីរីករាយនឹងចុះថ្លៃសៀវភៅ 20% ជូនសមាជិក ស.ស.ខ.

ហើយនឹងចុះថ្លៃជាពិសេសចំពោះសហករណ៍សិស្ស ។

សេចក្ដីអធិប្បាយខាងលើនេះ បញ្ជាក់ឲ្យឃើញថា ពួកអាណានិគមនិយមឆ្លាតណាស់ គេចេះបញ្ចូលឥទ្ធិពលគេទៅក្នុងស្រុកដែលគេត្រួត ដោយប្រើវិធីដាក់ស្នេហ៍តាមវប្បធម៌ជាធំ ពួកគេ „បាត់ទៅ គេក្ដីឈ្មោះគង់នៅ នឹងវប្បធម៌គេ ។ នេះហើយកម្លាំងឥទ្ធិពលនៃអាណានិគមនិយម ។

ប៉ុន្តែ ទោះបីឥទ្ធិពលទាំងនោះធំយ៉ាងណាក៏ដោយ ក៏វានៅជាឥទ្ធិពលនៃលទ្ធិប្រតិកិរិយា ពុករលួយជាទីស្អប់ខ្ពើមនៃមហាជនចំរើនភ្ញាក់រលឹកដដែល ។ នៅក្នុងលោកយើងនេះ គ្មានកម្លាំងអ្វីខ្លាំងជាងកម្លាំងមហាជន ដែលភ្ញាក់រលឹកហើយរួបរួមគ្នាទេ ។ ដូចនេះ ឥទ្ធិពលជិះជាន់មហាជនខាងលើនោះ គង់នឹងត្រូវគេវាយបំបាត់បោសសំអាតបានមិនខាន ។ នៅប្រទេសខ្មែរ ដែលធ្លាប់ទទួលការត្រួតត្រារបស់អាណានិគមនិយម ក្រោមការដឹកនាំរបស់សម្ដេចឪ ជាទីស្នេហាស្មើជីវិត ប្រជាជាតិខ្មែរបានដណ្ដើមយកឯករាជ្យ បានកសាងមាតុប្រទេសខ្លួនឡើងវិញគ្រប់មជ្ឈដ្ឋាន ហើយប្រសិនបើនៅសល់ឥទ្ធិពលអាណានិគមនិយមអម្បាញ់មិញខ្លះ ក៏សម្ដេច ឪ ព្រះអង្គនៅតែឈ្នះ បង្ក្រាបបានឲ្យវិនាសសោះសូន្យជាដាច់ខាត តាមកម្លាំងមហាជនស្នេហាសេចក្ដីចំរើនស្អាតស្អំ នឹងឯករាជ្យ ។ ការកែប្រែកម្មវិធីសិក្សាដែលកំពុងតែប្រព្រឹត្តទៅសព្វថ្ងៃ គឺការកែប្រែដើម្បីសម្របសម្រួលនឹងឯករាជ្យជាតិហើយ ។ នេះមិនគឺជាតឹកតាងមួយយ៉ាងច្បាស់លាស់ នៃជោគជ័យទៅលើឥទ្ធិពលអាណានិគមនិយមទេឬ ?

រួមសេចក្ដីមក ឥទ្ធិពលអាណានិគមនិយម មានអាយុយឺនយូរអង្វែងណាស់ នៅក្នុងប្រទេសនិមួយនិមួយ ដែលគេធ្លាប់ត្រួត ដោយគេប្រើវិធីបញ្ចូលឥទ្ធិពលតាមវប្បធម៌ ។ ប៉ុន្តែ ទោះបីមានកម្លាំងខ្លាំងយ៉ាងណាក៏ដោយ ក៏ឥទ្ធិពលនោះ នៅតែចាញ់កម្លាំងចំរើនរបស់មហាជនដែលស្នេហាសេរីភាព ឯករាជ្យជាតិដែរ ដូចប្រទេសខ្មែរ ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់ សម្ដេចឪជាដើម ។

# នៅស្ងៀមគឺថយក្រោយ


## ម៉ម បន្ទតា

និស្សិតសាស្ត្រាចារ្យ


ឲ្យតែយើងធ្វើមុខជាកើត    ឲ្យតែបង្កើតជាកើតបាន
ឲ្យតែយើងដើរដោយក្លាហាន    រាមុខជាបានទៅមុខហើយ ។
ខ្វះជាតិបាកពន់ពេកណាស់    ព្រោះពាក្យខ្មែរខ្វះពុំគ្រប់ឡើយ
ល្ហើយទ្រាំនៅស្ងៀមធ្វើកន្តើយ    បង្រៀនរៀនធ្វើយជាបារាំង ។
ឃើញថាពិបាកម្តេចមិនខំ    ឃើញថាការធំ - ធំយ៉ាងខ្លាំង
បែរជាមិនខំប្រឹងតតាំង    មើលឃើញគេខ្លាំងឱបដៃខ្លាច ។
បើគិតយ៉ាងនេះធ្វើអ្វីបាន    មុខជាខកប្រាណហើយបាត់ប្រាជ្ញ
នៅស្ងៀមមិនធ្វើមិនអង់អាច    មុខជាការសាបដះថយក្រោយ ។
ពាក្យខ្មែរមិនខ្វះបើយើងប្រើ    ពិបាកត្រូវធ្វើកុំបណ្តោយ
កុំចាំកុសលព្រេងផ្តល់ឲ្យ    បើចាំថ្ងៃក្រោយបាត់ពាក្យខ្មែរ ។
ខ្វះថាកុំអាលត្រូវយើងចាំ !    តើចាំដល់ឆ្នាំណាទៅដែរ ?
ឬចាំដល់បាត់ភាសាខ្មែរ    នោះតើយើងកែថាម៉េចយើង ?
ឃើញខ្លាហើយខ្លាចក្រាបសំពះ    មុខជាខ្លាទះដួលបះជើង
ឃើញខ្លាហើយខ្លាចទាញកាំភ្លើង    បាញ់ប៉ុងខ្លាប៉ើងយើងបានស្បែក ។
ប្រើទៅបើខ្វះខំបង្កើត    ខំប្រើកុំអើតចាំដល់ស្អែក
ប្រើពីឥឡូវទៅក្រោយបែក    ពាក្យកើតប្លែក ៗ សម្បូណ៌ប្រើ ។

# ត្រូវតែគិត

កែប វ៉ាន់ឌី

ខ្មែរមានវប្បធម៌ ខ្មែរមានអក្សរ
ខ្មែរមានភាសា ខ្មែរមានគំនិត
ចេះគិតចេះថា តាំងពីដូនតា
ច្រើនរយសតវត្ស ៗ

តែគួរអនិច្ចា មានគ្រាមួយណា
ខ្មែរបានជាភ្លាត់ ត្រូវពួកបារាំង
ចិត្តចោរចក្រពត្តិ ចូលមកសង្កត់
សង្កិនជាតិខ្មែរ ៗ

តាំងពីពេលនោះ វប្បធម៌ខ្មែរចុះ
រហូតទាល់តែ គេលែងទាំងស្គាល់
ថាមានជាតិខ្មែរ មួយនឹងគេដែរ
នៅក្នុងលោកនេះ ៗ

ចោរប្លន់ទឹកដី ចិត្តកាចអប្រិយ
មកនៅជាន់ជិះ រួចពោលបង្អាប់
ថាខ្មែរសំគិះ ថាខ្មែរមិនចេះ
ថាខ្មែរមិនឆ្លាត ៗ

ភថាវប្បធម៌ ភាសា - អក្សរ
ខ្មែរគ្មានក្បួនខ្នាត រៀនមិនចំរើន

នាំឲ្យតែខាត ទោះខំសង្វាត

ក៏មិនបេះដែរ ៗ

រួចហើយពួកវា ក៏តាំងបញ្ជា

ឲ្យកូនចៅខ្មែរ សិក្សាបារាំង

ដើម្បីបង្វែ ស្មារតីសិស្សខ្មែរ

ឲ្យភ្លេចជាតិខ្លួន ៗ

កំអែលបារាំង ចាក់ឫសរឹងតាំង

យ៉ាងខ្លាំងមាំមួន ព្រោះមានជាតិខ្មែរ

ល្ងក់[1]មួយចំនួន ស្រែកឡើងផ្ទួន ៗ

ថាបេះខ្មែរអន់ ៗ

ទោះនិយាយស្តី សរសេរក្តី ៗ

ខ្មែរល្ងក់យេពាន់ និយមបារាំង

ព្រោះថាមិនកាន់ ពាក្យគេគ្រប់គ្រាន់

វាងាយស្រួលស្តាប់ ៗ

គំនិតបែបនេះ ពិតជាសំគិះ

ព្រោះចង់សម្លាប់ វប្បធម៌ជាតិខ្លួន

ឲ្យសូន្យអានអាប់ ហើយមិនស្របច្បាប់

អ្នកជាតិនិយម ៗ

ខ្មែរឯកភាពហើយ មិនត្រូវកន្តើយ

ទោះខ្មែរតូច - ធំ សាមគ្គីបង្គាប់